# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១២-០១-២០១៣ -ព្រះរាជក្រម នស/រកម/០១១៣/០០១ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាស្តីពីការជូនដំណឹងជាបន្ទាន់ពីគ្រោះមហន្តរាយនុយក្លេអ៊ែរ និង អនុសញ្ញាស្តីពីសុវត្ថិភាពនុយក្លេអ៊ែរ ៧២១


### ២~ព្រះរាជក្រឹត្យ


០៤-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២៥ ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ដោយរក្សាមុខតំណែងជាអ្នកនយោបាយ ចំនួន ០៣ រូប ៧៦២

០៧-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២៧ ស្តីពី ការតែងតាំងជាសមាជិកបន្ថែម នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ចំនួន ០៨ រូប និង អនុញ្ញាតឱ្យឯកឧត្តម **ឡាយ សុខា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ លាឈប់ពីសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ និង តែងតាំងលោក **ឡាយ ប៊ុនថន** តំណាងក្រសួងមហាផ្ទៃ ជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរជំនួស ៧៦៣

០៧-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ ក្រសួងកិច្ចការនារី ចំនួន ០៣ រូប ៧៦៥

០៧-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចំនួន ៣០ រូប ៧៦៦

០៧-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ១៧៣ រូប ៧៦៧

០៧-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ឯកឧត្តម **សែម គីថាយ** ៧៧១

១០-០១-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះលោកជំទាវឧកញ៉ា **ជា សែន** ៧៧២

១០-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣៣ ស្ដីពី ការតែងតាំងឥស្សរជន ចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ពុំទទួលប្រាក់បៀវត្សរ៍ ៧៧៣

១០-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣៤ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឯកឧត្តម **ស្រី សួន** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១ ទៅឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ៧៧៤

១០-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះលោកបណ្ឌិត **LAlith Goonatilake** នាយកផ្នែកកសាងសមត្ថភាពពាណិជ្ជកម្ម នៃ អង្គការ UNIDO ៧៧៥

១០-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និង មន្ត្រីរាជការ ចំនួន ៥៦ រូប ៧៧៦

១០-០១-២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៣៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ឯកឧត្តម **សេខ ឈួន** ៧៧៩

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៥-០១-២០១៣ - អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៧៥២ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង កាត់ចេញពីគម្របព្រៃពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង) និង ចេញពីគម្របព្រៃឆ្នាំ ២០០២ និង ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៩៤ គ្រួសារ និង ការផ្ដល់សិទ្ធិលើក្បាលដី ៧៨០

១៧-០១-២០១៣ - អនុក្រឹត្យលេខ ២០ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៧៧៨ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម ក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សាម លីញ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១៨ គ្រួសារ ៧៨៣

១៧-០១-២០១៣ - អនុក្រឹត្យលេខ ២១ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៨០៦,៩៧ ហិកតា នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.០៤៩ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ៧៨៦

១៧-០១-២០១៣-អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ២.៦៩៨ ហិកតា នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និង កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ធីម៉ាស់ វីសូសលីមីធីត និង ធ្វើ អនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៤៩ គ្រួសារ ៧៩១

១៣-១១-២០១២-អនុក្រឹត្យលេខ **២៤៣៨** ដល់អនុក្រឹត្យលេខ **២៤៥២** អនក្រ.តត ស្តីពី ការជូន មេដាយការងារ ៧៩៤


## ២-សេចក្តីសំរេច


០៨-០១-២០១៣ -សេចក្តីសំរេចលេខ ០១ សសរ ស្តីពី ការជ្រើសរើសពលទាហាន ៨០៩

១១-០១-២០១៣-សេចក្តីសំរេចលេខ ០២ សសរ ស្តីពី ការជ្រើសរើសពលទាហាន ៨១០


## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


២០-១២-២០១២ -ប្រកាសលេខ ១២៤៣ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខូ-ស៊ីក ហ្គាមេន បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៨១១

២០-១២-២០១២ -ប្រកាសលេខ ១២៤៤ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អាយ អេស អាយ ស្មៀល បង្កើតរោងចក្រ ផលិតសង្កសី ,ដែក ៨១៥

២០-១២-២០១២ -ប្រកាសលេខ ១២៤៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.ខេ.ស៊ី. ជេ.វី. បង្កើតរោងចក្រ ផលិតសំបកដបពីប្លាស្ទិក,ច្រាសដុសធ្មេញ ៨១៩

២០-១២-២០១២ -ប្រកាសលេខ ១២៤៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាប់បែល យូ.លីងហ្គីរី & អាន់ជីវែ ហ្វេកធើរី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៨២៣


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៨-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៧០៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យាត ចាង** ៨២៧

០៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៧០៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្សាងរ៉ុង អ៊ិនធើណេសិនណល ហូលឌីង** ៨២៩

០៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៧០៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខា ហ្វាម៉ា** ៨៣១

០៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៧០៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណេគថ៍ គ្រេឌីត** ៨៣៣

០៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៧១១ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ប្រ៊្រីត សីលូសិន** ៨៣៥

០៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៧២១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊្វីធី អ៊ឹមផត អិចផត** ៨៣៧

០៩-៨-២០១១ -លិខិតបញ្ជាក់លេខ ៤៧២៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីលឌីង អេឡិតទ្រីខល អេនជីនារីង (ប៊ីអ៊ីអ៊ី)** ៨៣៩

# ព្រះរាជក្រម

នស/រកម/០១១៣/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្តីពីការជូនដំណឹងជាបន្ទាន់ពីគ្រោះមហន្តរាយនុយក្លេអ៊ែរ និងអនុសញ្ញាស្តីពីសុវត្ថិភាពនុយក្លេអ៊ែរ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្តីពីការជូនដំណឹងជាបន្ទាន់ពីគ្រោះមហន្តរាយនុយក្លេអ៊ែរ និងអនុសញ្ញាស្តីពីសុវត្ថិភាពនុយក្លេអ៊ែរ

**មាត្រា ១.-**

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃ ៖

- អនុសញ្ញាស្តីពីការជូនដំណឹងជាបន្ទាន់ពីគ្រោះមហន្តរាយនុយក្លេអ៊ែរ ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃសម័យប្រជុំពិសេស របស់ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិនៅទីក្រុងវីយ៉ែន នាថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៨៦
- អនុសញ្ញាស្តីពីសុវត្ថិភាពនុយក្លេអ៊ែរ ដែលត្រូវបានអនុម័តដោយសន្និសីទការទូតដែលធ្វើឡើងដោយទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ នាទីស្នាក់ការកណ្តាល នៅទីក្រុងវីយ៉ែន នាថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញាទាំងពីរនេះ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

[illegible].១៣០១.០៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់

លេខ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

[illegible] សុខា

**ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ**

បកប្រែក្រៅផ្លូវការ

**ការផ្សព្វផ្សាយព័ត៌មាន**

## អនុសញ្ញាស្តីពីការជូនដំណឹងជាបន្ទាន់ពីគ្រោះមហន្តរាយនុយក្លេអ៊ែរ

១.អនុសញ្ញាស្តីពី ការជូនដំណឹងជាបន្ទាន់ពីគ្រោះមហន្តរាយនុយក្លេអ៊ែរ ត្រូវបានអនុម័តដោយសន្និសីទការទូត សម័យប្រជុំរបស់ខ្លួន នៅថ្ងៃទី២៤-២៦ ខែសីហា ឆ្នាំ១៩៨៦ និងបើកឲ្យចុះហត្ថលេខានៅទីក្រុង វីយែន(Vienna) នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨៦ និង នៅទីក្រុង ញូវយ៉ក ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៨៦ ។ អនុសញ្ញានេះចូលជាធរមាន នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៨៦ ពោលគឺ ៣០ថ្ងៃបន្ទាប់ពីថ្ងៃទី ( ២៦ ខែសីហា ឆ្នាំ១៩៨៦) ដោយមានប្រទេស៣សម្តែងនូវការយល់ព្រមចំពោះការរៀបចំដោយមហាសន្និបាតដូចបានចែងក្នុងមាត្រា១២នៃអនុសញ្ញានេះ។

២.ខ្លឹមសារនៃអនុសញ្ញានេះគឺត្រូវបានយកចេញពីឯកសារថតចម្លងត្រឹមត្រូវ នឹងត្រូវបានចម្លងជូនសម្រាប់ជាព័ត៌មានជូនដល់សមាជិកទាំងអស់ ។

### អនុសញ្ញាស្តីពីការជូនដំណឹងជាបន្ទាន់ពីគ្រោះមហន្តរាយនុយក្លេអ៊ែរ

បណ្តារដ្ឋភាគីនៃអនុសញ្ញានេះត្រូវ៖

-ដឹងថាសកម្មភាពនុយក្លេអ៊ែរ កំពុងត្រូវបានគេអនុវត្តយ៉ាងសកម្មក្នុងបណ្តាប្រទេសមួយចំនួន

-កត់សម្គាល់ឃើញថា វិធានការដ៏ធំទូលាយកំពុងត្រូវបានគេធានាឲ្យបានប្រាកដនូវសុវត្ថិភាពកម្រិតខ្ពស់ ក្នុងសកម្មភាពនុយក្លេអ៊ែរ ក្នុងគោលបំណងទប់ស្កាត់គ្រោះមហន្តរាយនុយក្លេអ៊ែរ និងកាត់បន្ថយគ្រោះថ្នាក់ឲ្យមកនៅកម្រិតទាបបំផុត

-មានគោលបំណងពង្រឹងសហប្រតិបត្តិការអន្តរជាតិបន្ថែមទៀត ក្នុងការលើកកម្ពស់សុវត្ថិភាព និងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ

-ប្រាកដថាតម្រូវការសម្រាប់ប្រទេស គឺត្រូវផ្តល់ព័ត៌ពាក់ព័ន្ធ អំពីគ្រោះមហន្តរាយនុយក្លេអ៊ែរ ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ក្នុងគោលបំណង កាត់បន្ថយឲ្យមកនៅកម្រិតទាបបំផុតនូវផលវិបាកវិទ្យុសកម្ម ឆ្លងពីប្រទេសមួយទៅប្រទេសមួយ

-កត់សម្គាល់សារសំខាន់ នៃការរៀបចំជាពហុភាគី និងទ្វេភាគីស្តីពីការ ផ្លាស់ប្តូរព័ត៌មានក្នុងវិស័យនេះ ដោយបានឯកភាពគ្នាដូចតទៅ៖

### មាត្រា ១
### ទំហំនៃការអនុវត្ត

- អនុសញ្ញានេះត្រូវអនុវត្តក្នុងព្រឹត្តិការណ៍ នៃគ្រោះថ្នាក់ណាមួយពាក់ព័ន្ធ រោងចក្រ ឬសកម្មភាពនៃរដ្ឋភាគី ឬ រូបវន្តបុគ្គល ឬនីតិបុគ្គល ស្ថិតក្រោម យុត្តាធិការ ឬការគ្រប់គ្រងរបស់ខ្លួន យោងតាមកថាខណ្ឌ២ ខាងក្រោម ការលេចសាយភាយសារធាតុវិទ្យុសកម្ម ឬទំនងនឹងអាចកើតឡើង ដែលជាលទ្ធផល ឬជាលទ្ធផលនៃការលេចសាយភាយ ឆ្លងពីប្រទេសមួយទៅប្រទេសមួយ ក្នុងការធានាសុវត្ថិភាពវិទ្យុសកម្មសម្រាប់រដ្ឋមួយទៀត ។

- រោងចក្រ និង សកម្មភាពយោងក្នុង កថាខណ្ឌ ១ ដូចខាងក្រោម៖

ក. កន្លែងដែលម៉ាស៊ីនប្រតិកម្មនុយក្លេអ៊ែរស្ថិតនៅ ។

ខ. រោងចក្រចម្រាញ់សារធាតុនុយក្លេអ៊ែរ ។

គ. កន្លែងគ្រប់គ្រងកាកសំណល់សារធាតុវិទ្យុសកម្ម ។

ឃ. ការដឹកជញ្ជូន និងការស្តុកទុក កាកសំណល់វិទ្យុសកម្ម និង ឥន្ធនៈនុយក្លេអ៊ែរ ។

ង. ការផលិត ការប្រើប្រាស់ ការស្តុកទុក ការបំផ្លាញចោល និងការដឹកជញ្ជូនសារធាតុវិទ្យុសកម្ម សម្រាប់កសិកម្ម ឧស្សាហកម្ម វេជ្ជសាស្ត្រ សុខាភិបាល និងវិទ្យាសាស្ត្រ ដែលទាក់ទងនឹងគោលបំណងស្រាវជ្រាវពាក់ពន្ធ័នានា ។

ច. ការប្រើប្រាស់ រ៉ាឌីយូអ៊ីសូតូប សម្រាប់ថាមពលអគ្គីសនី ក្នុងលំហអាកាស ។

## មាត្រា២

## ការជូនដំណឹងនិងព័ត៌មាន

ក្នុងព្រឹត្តិការណ៍គ្រោះមហន្តរាយ ដូចបានចែងក្នុងមាត្រា ១(ហៅកាត់ថា " គ្រោះមហន្តរាយនុយក្លេអ៊ែរ ")រដ្ឋភាគី ដែលសំដៅក្នុងមាត្រានោះត្រូវ៖

ក.ជូនដំណឹងភ្លាមៗ ដោយផ្ទាល់ ឬតាមរយៈទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (ហៅកាត់ថា " ទីភ្នាក់ងារ ") បណ្តារដ្ឋទាំងនោះដែលត្រូវប៉ះពាល់ ដូចបានចែងក្នុងមាត្រា១ និងភ្នាក់ងារ នៃគ្រោះមហន្តរាយនុយក្លេអ៊ែរ ត្រូវវាយតម្លៃសភាពពិតរបស់វា ពេលវេលានៃការកើតឡើង និងទីតាំងពិតប្រាកដរបស់វាឲ្យបានត្រឹមត្រូវ។

ខ.ជូនដំណឹងយ៉ាងឆាប់រហ័ស ដល់បណ្តារដ្ឋ យោងតាម វាក្យខណ្ឌ (ក) ដោយផ្ទាល់ ឬតាមរយៈទីភ្នាក់ងារ និងភ្នាក់ងារ ដែលមានព័ត៌មានអាចប្រើប្រាស់បាន ជាប្រយោជន៍ទាក់ទិននឹងការកាត់បន្ថយគ្រោះថ្នាក់ទាបបំផុត នូវផលវិបាកវិទ្យុសកម្ម ក្នុងបណ្តារដ្ឋទាំងនោះ ដូចបានចែងក្នុងមាត្រា ៥ ។

## មាត្រា៣

## គ្រោះមហន្តរាយនុយក្លេអ៊ែរដទៃទៀត

ការកាត់បន្ថយគ្រោះថ្នាក់អប្បបរិមានូវផលវិបាកវិទ្យុសកម្ម រដ្ឋភាគីទាំងអស់ ត្រូវជម្រាបជូនពីព្រឹត្តិការណ៍ គ្រោះមហន្តរាយនុយក្លេអ៊ែរ លើសពីអ្វីដែលបានចែងក្នុងមាត្រា ១។

## មាត្រា៤

## តួនាទីទីភ្នាក់ងារ

ទីភ្នាក់ងារត្រូវ៖

ក. ជូនដំណឹងជាបន្ទាន់ដល់រដ្ឋភាគីទាំងអស់ ដែលអាចប៉ះពាល់ ដូចមានចែងក្នុងមាត្រា ១ និងអង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ដែលពាក់ពន្ធ័ទាំងអស់ (ហៅកាត់ថា" អង្គការអន្តរជាតិ" ) ទទួលបានការជូនដំណឹង ដោយអនុលោមទៅតាមវាក្យខណ្ឌ (ក) នៃមាត្រា ២ ។

ខ. ជូនដំណឹងយ៉ាងឆាប់រហ័ស ដល់បណ្តារដ្ឋ ភាគី និងសមាជិកផ្សេងទៀត ឬ អង្គការអន្តរជាតិពាក់ពន្ធ័ យោងតាមការស្នើសុំ តាមរយៈព័ត៌មានដែលទទួលបាន អនុលោមទៅតាមវាក្យខណ្ឌ (ខ) នៃមាត្រា ២ ។

## មាត្រា ៥
## ព័ត៌មាននិងការផ្តល់ព័ត៌មាន

១.ការផ្តល់ព័ត៌មានដល់រដ្ឋភាគីអនុលោមទៅតាមវាក្យខណ្ឌ (ខ) នៃមាត្រា២ ដែលមានទិន្នន័យដូចខាងក្រោម៖

ក. ពេលវេលាការវាយតម្លៃ ពីទីតាំងពិតប្រាកដឲ្យបានត្រឹមត្រូវ និងសភាពពិតនៃគ្រោះមហន្តរាយនុយក្លេអ៊ែរ ។

ខ. ទីកន្លែងរោងចក្រ ឬសកម្មភាពដែលពាក់ព័ន្ធ។

គ. សន្មត់ ឬ បង្កើតមូលហេតុ និងការវិវត្តដែលអាចដឹងទុកជាមុន នៃគ្រោះមហន្តរាយនុយក្លេអ៊ែរ ពាក់ព័ន្ធទៅនឹងការលេចសាយភាយសារធាតុវិទ្យុសកម្ម ឆ្លងពីប្រទេសមួយទៅប្រទេសមួយ។

ឃ. លក្ខណៈទូទៅនៃការលេចសាយភាយវិទ្យុសកម្ម រួមមាន រយៈចម្ងាយ សភាពពិត ប្រភេទគីមី និងប្រភេទរូបវ័ន្ត និងបរិមាណ សមាសភាគ និងផលប៉ះពាល់ខ្ពស់ នៃការសាយភាយចំហាយវិទ្យុសកម្ម ។

ង. ព័ត៌មានស្តីពីបច្ចុប្បន្ន នៃស្ថានភាពធារាសាស្ត្រ និងឧតុនិយមលក្ខ័ខ័ណ្ឌចាំបាច់ នៃការព្យាករ ការលេចសាយ ភាយសារធាតុវិទ្យុសកម្មឆ្លង ពីប្រទេសមួយទៅប្រទេសមួយ ។

ច. លទ្ធផល នៃការត្រួតពិនិត្យបរិស្ថានទាក់ទងនឹងការលេចសាយភាយ សារធាតុវិទ្យុសកម្មឆ្លងពីប្រទេសមួយទៅប្រទេសមួយ។

ឆ. ចាត់វិធានការការពារឬ មានផែនការទុកជាមុន ។

ជ. ការព្យាករ ក្នុងពេលមានការលេចសាយភាយសារធាតុវិទ្យុសកម្ម ។

២. ព័ត៌មាននេះ ត្រូវដាក់បន្ថែមនូវរយៈពេលឲ្យបានត្រឹមត្រូវ និងព័ត៌មានទាក់ទងបន្ថែមទៀត ស្តីពីការវិវត្ត នៃស្ថានភាពបន្ទាន់ រួមទាំងការបញ្ចប់ពិតប្រាកដ ឬ ដែលអាចព្យាករបាន ។

៣. ព័ត៌មានដែលទទួលបានអនុលោមទៅតាម វាក្យខណ្ឌ(ខ) នៃមាត្រា ២ អាចប្រើបាន ដោយមិនបានរឹតបន្តឹង លើកលែងតែ នៅពេលព័ត៌មាននោះ ត្រូវបានផ្តល់យ៉ាងជាក់ច្បាស់ ពីការជូនដំណឹងពីរដ្ឋភាគី ។

## មាត្រា៦
## ការពិគ្រោះពិភាក្សា

រដ្ឋភាគីត្រូវផ្តល់ព័ត៌មានអនុលោមទៅតាមវាក្យខ័ណ្ឌ(ខ) នៃមាត្រា ២ ត្រូវឆ្លើយតបភ្លាមៗ ទៅតាមសំណូមពរ សម្រាប់ព័ត៌មាន ឬ ការពិគ្រោះពិភាក្សាបន្ថែមទៀត ដែលស្នើសុំដោយរដ្ឋភាគី ដើម្បីកាត់បន្ថយការគ្រោះថ្នាក់នូវផលវិបាកវិទ្យុសកម្មក្នុងរដ្ឋនោះឲ្យមានកម្រិតទាបបំផុត ។

## មាត្រា៧
## អាជ្ញាធរមានសមត្ថកិច្ច និង ចំណុចទាក់ទង

១. រដ្ឋភាគីនីមួយៗ ត្រូវស្គាល់ ទីភ្នាក់ងារ និង បណ្តារដ្ឋភាគី ដទៃផ្សេងទៀត ដោយផ្ទាល់ ឬ តាមរយៈទីភ្នាក់ងារ អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន និងចំណុចទាក់ទងទទួលខុសត្រូវសម្រាប់ការចេញ និងទទួលការជូនដំណឹង និងព័ត៌មានយោងតាម មាត្រា២ ។ ចំណុចទាក់ទងទាំងនោះ និងចំណុចប្រសព្វ ស្ថិតនៅក្នុងដែនសមត្ថកិច្ច ភ្នាក់ងារត្រូវតែជាព័ត៌មាន ដែលគួរឲ្យទុកចិត្តបាន ។

២. រដ្ឋភាគីនីមួយៗ ត្រូវជូនដំណឹងឲ្យបានឆាប់រហ័សដល់ទីភ្នាក់ងារ នូវការប្រែប្រួលណាមួយដែលអាចកើតមានឡើង នៃព័ត៌មានយោងតាមមាត្រា ១ ។

៣. ភ្នាក់ងារ ត្រូវរក្សា បញ្ជីអាជ្ញាធរជាតិ និងគ្រប់គ្រង ចំណុចទាក់ទងព្រមទាំង ចំណុចទាក់ទងអង្គការ អន្តរជាតិ ពាក់ព័ន្ធនានា និងត្រូវផ្តល់បញ្ជីនិងចំណុចទាក់ទងទាំងនោះ ឲ្យទៅរដ្ឋភាគី និងរដ្ឋជាសមាជិក និង អង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀត ។

## មាត្រា៨
## ការជួយដល់រដ្ឋភាគី

ទីភ្នាក់ងារត្រូវ យោងតាមលក្ខន្តិកៈ និងតាមសំណើរបស់រដ្ឋភាគី ដែលមិនមានសកម្មភាពនុយក្លេអ៊ែរ ដោយខ្លួនឯង និងមានព្រំប្រទល់ជាប់នឹង ប្រទេស ដែលមានកម្មវិធីនុយក្លេអ៊ែរ ប៉ុន្តែមិនមែនជារដ្ឋសមាជិក ត្រូវតែធ្វើការ ស៊ើបអង្កេត ដែលអាចធ្វើទៅបាន និងបង្កើតប្រព័ន្ធត្រួតពិនិត្យចំហាយវិទ្យុសកម្មឲ្យបានត្រឹមត្រូវ ដើម្បីជួយសម្រួលដល់ការសម្រេចបានតាមគោលដៅ នៃអនុសញ្ញានេះ ។

## មាត្រា៩
## ការរៀបចំជាពហុភាគី និង ជាទ្វេភាគី

ដើម្បីផលប្រយោជន៍ទៅវិញទៅមករបស់ខ្លួន រដ្ឋភាគីទាំងអស់អាចពិចារណាទីកន្លែងដែលយល់ឃើញថាត្រឹមត្រូវ ការសន្និដ្ឋាន នៃការរៀបចំជាពហុភាគី និងជាទ្វេភាគី ទាក់ទិននឹងគោលបំណងនៃអនុសញ្ញានេះ ។

## មាត្រា១០
## ទំនាក់ទំនងចំពោះកិច្ចព្រមព្រៀងជាអន្តរជាតិ

អនុសញ្ញានេះនឹងមិនប៉ះពាល់សិទ្ធិទៅវិញទៅមក និងកាតព្វកិច្ចរបស់រដ្ឋភាគីទេ ដោយស្ថិតនៅក្រោមកិច្ចព្រមព្រៀង ដែលមានស្រាប់ ពាក់ព័ន្ធនឹងបញ្ហាដែលគ្របដណ្តប់ ដោយអនុសញ្ញានេះ ឬ ស្ថិតក្រោមកិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវបានរាប់បញ្ចូលនាពេលអនាគតដោយ ស្របតាមគោលដៅ និងគោលបំណងនៃអនុសញ្ញានេះ ។

## មាត្រា១១
## ដំណោះស្រាយជម្លោះ

១. ក្នុងព្រឹត្តិការណ៍មានជម្លោះរវាង រដ្ឋភាគី នឹងរដ្ឋភាគី ឬ រដ្ឋភាគី នឹងទីភ្នាក់ងារពាក់ព័ន្ធ និងបំណកស្រាយ ឬការអនុវត្ត នៃអនុសញ្ញានេះ រដ្ឋភាគីដែលមានជម្លោះ ត្រូវប្រឹក្សាស្វែងរកដំណោះស្រាយ ដោយការចចារ ឬ ដោយការ ដោះស្រាយជម្លោះ គ្រប់រូបភាពដោយសន្តិវិធី ដែលពួកគេអាចទទួលយកបាន ។

២. ប្រសិនបើជម្លោះតាមលក្ខណៈនេះរដ្ឋភាគី នឹងរដ្ឋភាគី មិនត្រូវបានដោះស្រាយក្នុងរយៈពេល ១ឆ្នាំ ចាប់ពីពេលមានសំណូមពរ ឲ្យមានការពិភាក្សាអនុលោមតាមកថាខណ្ឌ១ ត្រូវមានសំណូមពរ ពីរដ្ឋភាគីណាមួយ ដែលមានជម្លោះនោះត្រូវដាក់ជូន មជ្ឈត្តវិនិច្ឆ័យ ឬ ជូនទៅ តុលាការយុត្តិធម៌អន្តរជាតិ ដើម្បីរកដំណោះស្រាយ ។ ទីដែលជម្លោះ ត្រូវបានគេដាក់ជូនទៅ មជ្ឈត្តវិនិច្ឆ័យ ប្រសិនបើក្នុងរយៈពេល៦ខែ ពីថ្ងៃដាក់នោះរដ្ឋភាគីដែលមានជម្លោះ មិនអាច ឯកភាពលើ អង្គការមជ្ឈត្តវិនិច្ឆ័យបាន

ទេ រដ្ឋភាគីអាចស្នើទៅ ប្រធានតុលាការយុត្តិធម៌អន្តរជាតិ ឬ អគ្គលេខាធិការ អង្គការសហប្រជាជាតិដើម្បីតែងតាំង មជ្ឈត្តវិនិច្ឆ័យ១ឬ ២ទៀត ។ ក្នុងករណីមានវិវាទដែលស្នើដោយភាគីមានជម្លោះ ស្នើទៅ អគ្គលេខាធិការអង្គការសហប្រជាជាតិ គឺមានអាទិភាព ។

៣. ពេលចុះហត្ថលេខាផ្តល់សច្ចាប័ន ទទួលយកអនុម័ត ឬ យល់ព្រមចំពោះអនុសញ្ញានេះ រដ្ឋភាគីត្រូវប្រកាសថា មិនចាត់ទុកខ្លួនឯងជាចំណែកម្ខាង ឬ ចំណែកទាំងសងខាងនៃការដោះស្រាយជម្លោះ តាមនិតិវិធីដូចមានចែងក្នុងកថាខណ្ឌ២ ។ រដ្ឋភាគី ផ្សេងទៀតនឹងមិនត្រូវកំណត់ដោយនីតិវិធីដំណោះស្រាយជម្លោះដូចមានចែងក្នុងកថាខណ្ឌ២ ទេ ដោយគោរពដល់រដ្ឋភាគី ដែលមានសេចក្តីប្រកាសស្ថិតនៅជាធរមាន។

៤. រដ្ឋភាគីត្រូវធ្វើការប្រកាសស្របតាមកថាខណ្ឌ៣ និងអាចដកបានវិញគ្រប់ពេលវេលាដោយជូនដំណឹងទៅ អ្នកទទួលបញ្ញើ (depositary) ។

## មាត្រា១២
## ចូលជាធរមាន

១.អនុសញ្ញានេះនិងបើកឲ្យចុះហត្ថលេខាដោយបណ្តារដ្ឋទាំងអស់ និង ប្រទេសណាមីប៊ី ( Namibia) តំណាងដោយ ក្រុមប្រឹក្សាអង្គការសហប្រជាជាតិសម្រាប់ប្រទេសណាមីប៊ី( Namibia) នៅឯទីស្នាក់ការកណ្តាលភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ក្នុងទីក្រុងវីយែន ( Vienna) និងទីស្នាក់ការកណ្តាល អង្គការសហប្រជាជាតិនាទីក្រុងញូវយ៉ក ពីថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៨៦ និង ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៨៦ ផ្សេងមួយទៀត រហូតដល់ចូលជាធរមានឬ រយៈពេល ១២ ខែ ពេលណាមួយដែលយូរជាង ។

២. រដ្ឋ និងប្រទេសណាមីប៊ី( Namibia)តំណាងដោយ ក្រុមប្រឹក្សាអង្គការសហប្រជាជាតិប្រចាំ ប្រទេសណាមីប៊ី( Namibia) អាចសម្តែងនូវការយល់ព្រមរបស់ខ្លួនចំពោះអនុសញ្ញានេះតាមរយៈការចុះហត្ថលេខា ឬ ដាក់ចូលលិខិតូបករណ៍ នៃសច្ចាប័ន ការទទួលយក ការអនុម័ត បន្ទាប់ពីការចុះហត្ថលេខាដល់សច្ចាប័ននេះ ការទទួលយក ការអនុម័ត ដោយការដាក់ចូលលិខិតូបករណ៍ សម្រាប់ការយល់ព្រម ។ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការយល់ព្រមនឹងត្រូវដាក់ចូលនៅ អ្នកទទួលបញ្ញើ( depositary) ។

៣. អនុសញ្ញានេះ នឹងចូលជាធរមាន ៣០ថ្ងៃបន្ទាប់ពី ការយល់ព្រមត្រូវបានឯកភាពពីប្រទេសទាំង៣រួចមក។

៤. ចំពោះប្រទេសនីមួយៗ ដែលសម្តែងការយល់ព្រមលើអនុសញ្ញានេះ បន្ទាប់ការចូលជាធរមានមក អនុសញ្ញានេះ និងចូលជាធរមានសម្រាប់រដ្ឋនោះ ៣០ថ្ងៃបន្ទាប់ពីថ្ងៃដែលបានយល់ព្រមរួច ។

៥.

ក. អនុសញ្ញានេះនឹងបើកឲ្យមានការយល់ព្រម ដូចបានចែងក្នុងមាត្រានេះដោយ អង្គការអន្តរជាតិ និង អង្គការសមាហរណកម្មតំបន់នានា ដែលជារដ្ឋអធិបតេយ្យមានសមត្ថកិច្ចក្នុងការចរចាសម្រេច និងអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិរាល់បញ្ហាដែលបានគ្របដណ្តប់ក្នុង អនុសញ្ញានេះ ។

ខ. រាល់បញ្ហាក្នុងដែនសមត្ថកិច្ចក្នុងអង្គការនោះ ក្នុងនាមខ្លួនគេផ្ទាល់ ត្រូវធ្វើការិយកម្មសិទ្ធិ និងបំពេញកាតព្វកិច្ច ដូចដែលអនុសញ្ញានេះបានកំណត់ដល់រដ្ឋភាគីទាំងអស់ ។

គ. ពេលដាក់លិខិតូបករណ៍នៃការយល់ព្រមរបស់ខ្លួនរួច អង្គការនោះ នឹងទំនាក់ទំនងទៅកាន់អ្នកទទួលបញ្ញើ (depositary) ដោយធ្វើសេចក្តីប្រកាស ដើម្បីបង្ហាញពីទំហំ ពីសមត្ថកិច្ចរបស់ខ្លួនដែលមានវិសាលភាពក្នុងអនុសញ្ញានេះ ។

ឃ. អង្គការនោះនឹងមិនបោះឆ្នោតថែមទៀតដល់ប្រទេសទាំងនោះដែលជាសមាជិករបស់ខ្លួនទេ ។

## មាត្រា១៣
## បទប្បញ្ញត្តិដែលត្រូវអនុវត្ត

រដ្ឋ ដែលបានចុះហត្ថលេខាមុន ឬ ក្រោយថ្ងៃដែលអនុសញ្ញានេះចូលជាធរមាន ត្រូវប្រកាសថា ខ្លួនត្រូវអនុវត្តតាម អនុសញ្ញានេះ។

## មាត្រា១៤
## វិសោធនកម្ម

១.រដ្ឋភាគីអាចស្នើសុំធ្វើវិសោធនកម្មទៅនឹងអនុសញ្ញានេះបាន ។ វិសោធនកម្មដែលត្រូវបានស្នើសុំអាចដាក់ជូនទៅកន្លែងអ្នកទទួលបញ្ញើ(depositary) ដែលអាចផ្សព្វផ្សាយភ្លាមៗទៅបណ្តារដ្ឋភាគីផ្សេងទៀត ។

២. ប្រសិនបើមតិភាគច្រើននៃរដ្ឋភាគី ស្នើសុំទៅអ្នកទទួលបញ្ញើ (depositary) ដើម្បីប្រជុំពិចារណា វិសោធនកម្មដែលត្រូវបានស្នើសុំអ្នកទទួលបញ្ញើ (depositary) និងអញ្ជើញរដ្ឋភាគីទាំងអស់ ឲ្យចូលរួមកិច្ចប្រជុំនោះដើម្បីចាប់ផ្តើមមិនឲ្យហួសពី ៣០ថ្ងៃ បន្ទាប់ពីការអញ្ជើញហើយ។ ការធ្វើវិសោធនកម្មណាមួយបានអនុម័ត នាសម័យប្រជុំនោះដោយមតិភាគច្រើន ២ ភាគ ៣ នៃរដ្ឋភាគីទាំងអស់ នឹងត្រូវបានប្រកាសជាផ្លូវការក្នុងពិធីសារដែលបានបើកឲ្យចុះហត្ថលេខា ក្នុងទីក្រុង វីយែន (Vienna) និងទីក្រុង ញូវយ៉ក ដោយរដ្ឋភាគីទាំងអស់ ។

៣. ពិធីសារនឹងចូលជាធរមាន ៣០ថ្ងៃ បន្ទាប់ពីមានការយល់ព្រមធ្វើឡើងដោយរដ្ឋទាំង៣ ។ ចំពោះរដ្ឋនីមួយៗ ដែលបានសម្តែងការយល់ព្រមដោយពិធីសារបន្ទាប់ពីការចូលជាធរមាន ពិធីសារនឹងចូលជាធរមាន ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានយល់ព្រមរួច ។

## មាត្រា១៥
## ការបដិសេធ

១.រដ្ឋភាគីអាចប្រកាសបដិសេធចំពោះអនុសញ្ញានេះ ដោយការជូនដំណឹងជាផ្លូវការជាលាយលក្ខណ៍អក្សរទៅអ្នកទទួលបញ្ញើ(depositary) ។

២.ការប្រកាសបដិសេធនឹងចូលជាធរមាននៅឆ្នាំបន្ទាប់ក្រោយ ពីថ្ងៃជូនដំណឹង ដែលត្រូវបានទទួលដោយអ្នកទទួលបញ្ញើ (depositary) ។

## មាត្រា១៦
## អ្នកទទួលបញ្ញើ

១. អគ្គនាយក ទីភ្នាក់ងារ នឹងធ្វើជាអ្នកទទួលបញ្ញើ (depositary) នៃអនុសញ្ញានេះ ។

២. អគ្គនាយក ទីភ្នាក់ងារ នឹងជូនដំណឹងភ្លាមៗ ដល់រដ្ឋភាគីទាំងអស់ និង បណ្តារដ្ឋផ្សេងទៀតមានៈ

ក. ការចុះហត្ថលេខានីមួយៗនៃអនុសញ្ញានេះ ឬ ពិធីសារនៃការធ្វើវិសោធនកម្ម ។

ខ. ការដាក់លិខិតូបករណ៍នីមួយៗ នៃសច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការយល់ព្រម ពាក់ព័ន្ធនឹងអនុសញ្ញានេះ នៃពិធីសារណាមួយ នៃវិសោធនកម្ម ។

គ. ការប្រកាស ឬ ការដកចេញណាមួយ ត្រូវធ្វើស្របតាមមាត្រា ១១ ។

ឃ. ការប្រកាស នៃការអនុវត្តអនុសញ្ញានេះអនុលោមតាមមាត្រា១៣ ។

ង. ការចូលជាធរមាននៃអនុសញ្ញានេះ និងការធ្វើវិសោធនកម្ម ។

ច. ការប្រកាសបដិសេធ ធ្វើឡើងស្ថិតក្រោមមាត្រា ១៥ ។

## មាត្រា១៧
## អត្ថបទដើម និងឯកសារបញ្ជាក់ត្រឹមត្រូវ

ប្រភពដើមនៃអនុសញ្ញានេះរួមមានភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង ភាសា អេស្ប៉ាញ គឺជាអត្ថបទ មានតម្លៃស្មើ នឹងត្រូវបានដាក់ជូន អគ្គនាយក នៃទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិហើយធ្វើជូនឯកសារចម្លង ត្រឹមត្រូវតាមច្បាប់ដើម ទៅកាន់ រដ្ឋភាគីទាំងអស់ និងបណ្តារដ្ឋដទៃទៀត ។

ទុកជាសាក្សី ការចុះហត្ថលេខាពីក្រោម ត្រូវបានគេផ្តល់សិទ្ធិយ៉ាងត្រឹមត្រូវ ដើម្បីចុះហត្ថលេខាលើអនុសញ្ញានេះ បើកឲ្យចុះហត្ថលេខា ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រា ១២។

ត្រូវបានអនុម័តដោយមហាសន្និបាត នៃសម័យប្រជុំពិសេស របស់ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ នៅទីក្រុង វីយែន (Vienna) នាថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៨៦ ។

**ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ** បកប្រែក្រៅផ្លូវការ

**ការផ្សព្វផ្សាយព័ត៌មាន**

## អនុសញ្ញាស្តីពីសុវត្ថិភាពនុយក្លេអ៊ែរ

១. អនុសញ្ញាស្តីពីសុវត្ថិភាពនុយក្លេអ៊ែរ ត្រូវបានអនុម័តនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៤ ក្នុងសន្និសីទការទូតមួយដែលធ្វើឡើង ដោយទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ នាទីស្នាក់ការកណ្តាលនៅទីក្រុងវីយែន នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៤។ អនុសញ្ញានេះបានបើកឲ្យចុះហត្ថលេខានៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៤ ក្នុងអំឡុងពេលសម័យប្រជុំលើកទី៣៨ នៃសន្និសីទរបស់ទីភ្នាក់ងារ នឹងចូលជាធរមាន៩០ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ជូនអ្នកទទួលបញ្ញើ(depositary) (អគ្គនាយកទីភ្នាក់ងារ) លិខិតូបករណ៍ទី២២ នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការអនុម័តរួមទាំងលិខិតូបករណ៍នានា នៃរដ្ឋទាំង១៧ ដោយយ៉ាងហោចណាស់ប្រទេសនីមួយៗ មានរោងចក្រនុយក្លេអ៊ែរ ដែលបានសម្រេចជោគជ័យយ៉ាងធំធេងក្នុងវិស័យថាមពលនុយក្លេអ៊ែរ ។

២. ខ្លឹមសារនៃអនុសញ្ញាដូចបានអនុម័ត ត្រូវបានថតចម្លងក្នុង ឧបសម្ព័ន្ធ សម្រាប់ជាព័ត៌មានដល់បណ្តាជាសមាជិកទាំងអស់

### បុព្វកថា

**ភាគីជាប់កិច្ចសន្យា**

(១)ត្រូវយល់ដឹងពីសារសំខាន់ចំពោះសហគមន៍អន្តរជាតិ ដោយធានាថាការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ប្រកបដោយសុវត្ថិភាព ព្រមទាំងមានបទដ្ឋានគតិយុត្តត្រឹមត្រូវ។

(២) បញ្ជាក់សារជាថ្មីនូវការចាំបាច់ក្នុងការបន្តលើកកម្ពស់សុវត្ថិភាពនុយក្លេអ៊ែរឲ្យបានកម្រិតខ្ពស់ទូទាំងពិភពលោក ។

(៣)បញ្ជាក់សារជាថ្មីថាការទទួលខុសត្រូវសម្រាប់សុវត្ថិភាពនុយក្លេអ៊ែរទៅនឹងរដ្ឋ ដែលមានយុត្តាធិការលើរោងចក្រថាមពលនុយក្លេអ៊ែរ។

(៤) មានបំណងលើកកម្ពស់វប្បធម៌សុវត្ថិភាពនុយក្លេអ៊ែរឲ្យមានប្រសិទ្ធភាព។

(៥) ត្រូវយល់ដឹងថា គ្រោះមហន្តរាយនៅឯរោងចក្រថាមពលនុយក្លេអ៊ែរ មានសក្តានុពលភាព ធ្វើឲ្យប៉ះពាល់ ឆ្លងពី ប្រទេសមួយទៅប្រទេសមួយ។

(៦)ក្នុងស្មារតី នៃអនុសញ្ញាស្តីពីការការពាររូបវន្តវត្ថុធាតុនុយក្លេអ៊ែរឆ្នាំ (១៩៧៩) អនុសញ្ញាស្តីពីការជូនដំណឹងជាបន្ទាន់នៃគ្រោះមហន្តរាយនុយក្លេអ៊ែរឆ្នាំ(១៩៨៦) និងអនុសញ្ញាស្តីពីការជួយក្នុងករណីគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬសង្គ្រោះបន្ទាន់ផ្នែកវិទ្យុសកម្មឆ្នាំ(១៩៨៦) ។

(៧) បញ្ជាក់ថាសារៈសំខាន់ នៃសហប្រតិបត្តិការអន្តរជាតិសម្រាប់លើកកម្ពស់សុវត្ថិភាពនុយក្លអ៊ែរ តាមរយៈយន្តការ ពហុភាគី និងទ្វេភាគី និងការបង្កើតឡើងនូវអនុសញ្ញានេះ។

(៨) ទទួលស្គាល់ថាអនុសញ្ញានេះ តម្រូវឲ្យប្តេជ្ញាអនុវត្តគោលការណ៍សុវត្ថិភាពជាមូលដ្ឋាន សម្រាប់រោងចក្រ ថាមពលនុយក្លេអ៊ែរជាជាង ស្តង់ដារសុវត្ថិភាពពិស្តារ នឹងត្រូវបានគេរៀបចំយ៉ាងជាក់លាក់ជាអន្តរជាតិពីគោលការណ៍ ណែនាំដែលកែប្រែពីពេលមួយ ទៅពេលមួយដើម្បីអាចផ្តល់នូវការណែនាំស្តីពីសហសម័យគ្រប់មធ្យោបាយ ក្នុងការសម្រេចឲ្យបានសុវត្ថិភាពកម្រិតខ្ពស់។

(៩)បញ្ជាក់ថាតម្រូវការចាប់ផ្តើមភ្លាមៗធ្វើអនុសញ្ញាអន្តរជាតិស្តីពីសុវត្ថិភាព នៃការគ្រប់គ្រងកាកសំណល់ វិទ្យុសកម្ម ពេលដំណើរការកំពុងចាប់ផ្តើម បង្កើតសុវត្ថិភាពគ្រប់គ្រងកាកសំណល់ជាមូលដ្ឋានឲ្យទទួលបាន កិច្ចព្រមព្រៀងអន្តរជាតិយ៉ាងទូលំទូលាយ។

(១០)ទទួលស្គាល់សារប្រយោជន៍នៃការងារបច្ចេកទេសបន្ថែមទៀត ក្នុងការទំនាក់ទំនងឲ្យមានសុវត្ថិភាព លើផ្នែកដទៃទៀតនៃការចម្រាញ់ឥន្ធនៈនុយក្លេអ៊ែរ ហើយការងារនេះនឹងជួយសម្រួលទាន់ពេលវេលាដល់ការអភិវឌ្ឍ លិខិតូបករណ៍ អន្តរជាតិនាពេលបច្ចុប្បន្ន និងអនាគត ។

**បានយល់ព្រមដូចតទៅ ៖**

## ជំពូក១ : គោលបំណង និយមន័យ និង ទំហំនៃការអនុវត្ត

### មាត្រា១. គោលបំណង

គោលបំណងនៃអនុសញ្ញានេះ ៖

(១)សម្រេចឲ្យបាន និងរក្សាឲ្យបានសុវត្ថិភាពនុយក្លេអ៊ែរកម្រិតខ្ពស់ទូទាំងពិភពលោកតាមរយៈការលើកកម្ពស់ វិធានការជាតិ និងសហប្រតិបត្តិការអន្តរជាតិរួមទាំងសុវត្ថិភាពទាក់ទងនឹងសហប្រតិបត្តិការបច្ចេកទេសត្រឹមត្រូវ ។

(២)បង្កើតឡើង និងការពារឲ្យមានប្រសិទ្ធភាពចំពោះ រោងចក្រថាមពលនុយក្លេអ៊ែរ ប្រឆាំងនឹងគ្រោះថ្នាក់វិទ្យុសកម្ម ដើម្បីការពារបុគ្គល សង្គម និងបរិស្ថានពីផលប៉ះពាល់ចំហាយវិទ្យុសកម្ម ពីរោងចក្រថាមពលនុយក្លេអ៊ែរ ។

(៣) ការពារគ្រោះមហន្តរាយជាមួយនឹងផលវិបាកវិទ្យុសកម្ម និងកាត់បន្ថយផលវិបាកប្រសិនបើកើតមានឡើង ។

### មាត្រា២: និយមន័យ

គោលបំណងនៃអនុសញ្ញានេះ ៖

(១)"រោងចក្រថាមពលនុយក្លេអ៊ែរ" សំដៅដល់បណ្តាភាគីជាប់កិច្ចសន្យា រោងចក្រផលិតថាមពលនុយក្លេអ៊ែរស៊ីវិលដែលមានមូលដ្ឋានលើប្រទេសស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន រួមទាំងការស្តុកទុក ការកាន់កាប់ ចាត់ចែងសារធាតុវិទ្យុសកម្ម នៅកន្លែងតែមួយ ទាក់ទងផ្ទាល់ទៅនឹងប្រតិបត្តិការ រោងចក្រផលិតថាមពលនុយក្លេអ៊ែរ។ រោងចក្របែបនោះត្រូវតែបញ្ឈប់ជារោងចក្រថាមពលនុយក្លេអ៊ែរ នៅពេលដែលវត្ថុធាតុឥន្ធនៈនុយក្លេអ៊ែរទាំងអស់នោះ ត្រូវបានគេយកចេញជាអចិន្ត្រៃយ៍ពីស្នូល (core)ម៉ាស៊ីនប្រតិកម្ម និងត្រូវស្តុកទុកឲ្យមានសុវត្ថិភាពស្របតាមនីតិវិធីដែលបានអនុម័តហើយនឹងត្រូវបញ្ឈប់កម្មវិធីដែលបានយល់ព្រមរួចដោយគណៈកម្មការនិយ័តកម្ម។

(២)"គណៈកម្មការនិយ័តកម្ម" សំដៅដល់បណ្តាភាគីជាប់កិច្ចសន្យាទាំងឡាយ គណៈកម្មការណាមួយ ដែលត្រូវបានគេផ្តល់តាមផ្លូវច្បាប់ ដែលភាគីជាប់កិច្ចសន្យាទទួលបានសិទ្ធិ និងធ្វើនិយ័តកម្ម លើការរៀបចំ ការសាងសង់ ការប្រគល់អំណាចប្រតិបត្តិការ និងការបញ្ឈប់រោងចក្រថាមពលនុយក្លេអ៊ែរ។

(៣) អាជ្ញាប័ណ្ណ សំដៅដល់អំណាចណាមួយដែលបានពីគណៈកម្មការនិយ័តកម្ម ជូនដល់អ្នកអនុវត្តឲ្យទទួលខុសត្រូវការផ្តល់ទីតាំង ការរៀបចំ ការសាងសង់ ការប្រគល់អំណាច ប្រតិបត្តិការ និងការបញ្ឈប់រោងចក្រថាមពល នុយក្លេអ៊ែរ។

### មាត្រា៣. ទំហំនៃ ការអនុវត្ត

អនុសញ្ញានេះនឹងអនុវត្តចំពោះសុវត្ថិភាពរោងចក្រថាមពលនុយក្លេអ៊ែរ

## ជំពូក២. ភាតព្វកិច្ច

### (ក) បទប្បញ្ញត្តិទូទៅ

### មាត្រា៤.ការអនុវត្ត នៃវិធានការ

បណ្តាភាគីជាប់កិច្ចសន្យាត្រូវចាត់វិធានការតាមផ្លូវច្បាប់ជាតិ លើផ្នែករដ្ឋបាល និងនិយ័តកម្ម និងវិធានការចាំបាច់ផ្សេងទៀត សម្រាប់ការអនុវត្តនូវកាតព្វកិច្ចស្ថិតក្រោមអនុសញ្ញានេះ ។

### មាត្រា៥.សេចក្តីរាយការណ៍

បណ្តាភាគីជាប់កិច្ចសន្យាត្រូវ ដាក់ជូននូវរបាយការណ៍ត្រួតពិនិត្យឡើងវិញ ឲ្យបានមុនកិច្ចប្រជុំដូចបានចែង ក្នុងមាត្រា ២០ ស្តីពីការចាត់វិធានការ ដើម្បីអនុវត្តនូវកាតព្វកិច្ចនៃអនុសញ្ញានេះ។

### មាត្រា៦. រោងចក្រនុយក្លេអ៊ែរដែលកំពុងដំណើរការ

បណ្តាភាគីជាប់កិច្ចសន្យាត្រូវចាត់វិធានការឲ្យបានសមរម្យ និងធ្វើឲ្យប្រាកដថាមានសុវត្ថិភាពចំពោះ រោងចក្រនុយក្លេអ៊ែរដែលកំពុងដំណើរការចំពេលដែលអនុសញ្ញានេះចូលជាធរមាន ភាគីជាប់កិច្ចសន្យាត្រូវបានគេពិនិត្យសារជាថ្មីឡើងវិញឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។ ពេលចាំបាច់នៅក្នុងខ្លឹមសារនៃអនុសញ្ញានេះ ភាគីជាប់កិច្ចសន្យាត្រូវធ្វើឲ្យប្រាកដថា ត្រូវធ្វើឲ្យបានប្រសើរ ជាបន្ទាន់ដើម្បីលើកកម្ពស់សុវត្ថិភាពដល់រោងចក្រនុយក្លេអ៊ែរ។ ប្រសិនបើការលើកកម្ពស់នោះមិនអាចទទួលបានជោគជ័យ ផែនការដែលនឹងត្រូវអនុវត្តគឺបិទរោងចក្រនុយក្លេអ៊ែរ ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ពេលវេលានៃការបិទនឹងអាចយកមកពិចារណាលើខ្លឹមសារទាំងមូល និងជម្រើសផ្សេងទៀត ព្រមទាំងផលប៉ះពាល់លើសេដ្ឋកិច្ច បរិស្ថាន និងសង្គម។

### (ខ) នីតិកម្ម និងបទបញ្ជា

### មាត្រា៧. ទម្រង់នីតិកម្ម និងបទបញ្ជា

១.បណ្តាភាគីជាប់កិច្ចសន្យា ត្រូវបង្កើតនិងរក្សានូវទម្រង់នីតិកម្ម និងបទបញ្ជា ដើម្បីគ្រប់គ្រងសុវត្ថិភាពរោងចក្រនុយក្លេអ៊ែរ ។
២.ទម្រង់នីតិកម្ម និងបទបញ្ជាត្រូវផ្តល់នូវៈ

(១) ការបង្កើតឡើងនូវការអនុវត្តតម្រូវការសុវត្ថិភាពជាតិ និង បទបញ្ជា។

(២) ចំណាត់ថ្នាក់អាជ្ញាប័ណ្ណចំពោះរោងចក្រនុយក្លេអ៊ែរ និង ការហាមប្រាមប្រតិបត្តិការ រោងចក្រនុយក្លេអ៊ែរ ដោយគ្មានអាជ្ញាប័ណ្ណ ។

(៣) ត្រួតពិនិត្យបទបញ្ជា និង ការប៉ាន់ប្រមាណលើរោងចក្រនុយក្លេអ៊ែរ ចំពោះការអនុវត្តឲ្យបាន ត្រឹមត្រូវជាមួយបទបញ្ជា និងអាណត្តិ នៃអាជ្ញាប័ណ្ណ ។

(៤) ការអនុវត្តច្បាប់ ដែលចូលជាធរមានបទបញ្ជានិងអាណត្តិ នៃអាជ្ញាប័ណ្ណ រួមមានការផ្អាក ការកែប្រែ ឬ ការដកហូតមកវិញ ។

### មាត្រា៨. គណៈកម្មការនិយ័តកម្ម

១.បណ្តាភាគីជាប់កិច្ចសន្យា ត្រូវបង្កើត ឬ រៀបចំគណៈកម្មការនិយ័តកម្ម ដើម្បីប្រគល់ជូនឲ្យការអនុវត្តច្បាប់ បទបញ្ជាដូចមានចែងក្នុងមាត្រា៧ និងផ្តល់ជូន ហិរញ្ញវត្ថុ សមត្ថកិច្ច សិទ្ធិអំណាចឲ្យបានគ្រប់គ្រាន់ និងធនធានមនុស្ស ដើម្បីទទួលខុស

ត្រូវរៀងៗខ្លួន។

២. បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា មានការដាច់ពីគ្នាស្រឡះ រវាងតួនាទីរបស់ គណៈកម្មការនិយ័តកម្ម និង គណៈកម្មការ ឬ អង្គការផ្សេងទៀតដែលពាក់ពន្ធ័ជាមួយការផ្សព្វផ្សាយ និងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ។

**មាត្រា៩. ការទទួលខុសត្រូវនៃអ្នកកាន់កាប់អាជ្ញាប័ណ្ណ**

បណ្តាភាគីជាប់កិច្ចសន្យា ត្រូវធ្វើឲ្យបានប្រាកដថា ការទទួលខុសត្រូវចម្បងសម្រាប់ សុវត្ថិភាព រោងចក្រនុយក្លេអ៊ែររួមជាមួយអ្នកកាន់កាប់អាជ្ញាប័ណ្ណពាក់ព័ន្ធ ត្រូវចាត់វិធានការឲ្យបានសមរម្យ និងធ្វើឲ្យប្រាកដថា អ្នកកាន់កាប់អាជ្ញាប័ណ្ណនីមួយៗ ធ្វើតាមការទទួលខុសត្រូវរបស់ខ្លួន ។

**(គ) សុវត្ថិភាពទូទៅ**

**មាត្រា១០. អាទិភាពសុវត្ថិភាព**

១. បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា អង្គការទាំងអស់បានចូលរួម ក្នុងសកម្មភាពផ្ទាល់ទាក់ទងនឹងរោងចក្រនុយក្លេអ៊ែរ និងត្រូវបង្កើតគោលនយោបាយដែលអាចផ្តល់អាទិភាព តាមពេលដែលសមស្រប ចំពោះសុវត្ថិភាពនុយក្លេអ៊ែរ ។

**មាត្រា១១. ហិរញ្ញវត្ថុ និង ធនធានមនុស្ស**

១. បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់គាំពារដល់ដំណើរការរបស់ខ្លួន អំពីសុវត្ថិភាពរោងចក្រនុយក្លេអ៊ែរនីមួយៗ ។

២. បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា មានចំនួនបុគ្គលិកមានសមត្ថភាពគ្រប់គ្រាន់ ដោយមានការសិក្សាសមរម្យ ការហ្វឹកហាត់ និងការហ្វឹកហាត់សារជាថ្មី ដែលអាចធ្វើបានសម្រាប់សកម្មភាពទាក់ទងទៅនឹងសុវត្ថិភាព និងសម្រាប់រោងចក្រនុយក្លេអ៊ែរនីមួយៗ ក្នុងដំណើរការរបស់ខ្លួន ។

**មាត្រា១២. កត្តាមនុស្ស**

បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា សមត្ថភាពនិងការកំណត់នៃសមត្ថភាពធ្វើការងាររបស់បុគ្គលិក ត្រូវពិចារណាក្នុងដំណើរការនៃរោងចក្រនុយក្លេអ៊ែរ ។

**មាត្រា១៣. ការធានាគុណភាព**

បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យកម្មវិធីធានាគុណភាព ត្រូវបង្កើតឡើង និងអនុវត្តក្នុងបំណងផ្តល់ទំនុកចិត្ត អំពីតម្រូវការច្បាស់លាស់សម្រាប់សកម្មភាពសំខាន់ៗទាំងអស់ចំពោះសុវត្ថិភាពនុយក្លេអ៊ែរ ដែលត្រូវបានបំពេញឲ្យដំណើរការរោងចក្រនុយក្លេអ៊ែរ ។

**មាត្រា១៤. ការវាយតម្លៃ និងការផ្ទៀងផ្ទាត់ នៃសុវត្ថិភាព**

បណ្តាភាគីជាប់កិច្ចសន្យាត្រូវចាត់វិធានការឲ្យសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា៖

(១) ការវាយតម្លៃសុវត្ថិភាពជាប្រព័ន្ធ និងធំទូលាយ ត្រូវបានគេអនុវត្តមុនការសាងសង់ និងការប្រព្រឹត្តទៅនៃរោងចក្រនុយក្លេអ៊ែរក្នុងដំណើរការរបស់ខ្លួន ។ ការប៉ាន់ប្រមាណនោះត្រូវធ្វើជាឯកសារឲ្យបានល្អ កែតម្រូវឲ្យបានជាប្រចាំដោយប្រតិបត្តិការតាមពិសោធន៍ និងព័ត៌មានសុវត្ថិភាពសំខាន់ៗថ្មី និងត្រួតពិនិត្យឡើងវិញ ស្ថិតក្រោមសិទ្ធិអំណាចរបស់គណៈកម្មការនិយ័តកម្ម ។

(២) ការផ្ទៀងផ្ទាត់ ដោយការវិភាគ ការស៊ើបអង្កេត ការសាកល្បង និងការត្រួតពិនិត្យ ត្រូវបានគេអនុវត្តឲ្យប្រាកដថា លក្ខណៈច្បាប់ និងប្រតិបត្តិការនៃរោងចក្រនុយក្លេអ៊ែរអាចបន្តស្របតាមការរៀបចំតម្រូវការអនុវត្តសុវត្ថិភាពថ្នាក់ជាតិ និងល័ក្ខខ័ណ្ឌ និងការកំណត់ប្រតិបត្តិការ ។

## មាត្រា១៥. ការការពារចំហាយវិទ្យុសកម្ម

បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យដើម្បីធ្វើឲ្យប្រាកដថា រាល់ប្រតិបត្តិការ នៃការចេញចំហាយវិទ្យុសកម្មទៅលើកម្មករ និងសាធារណជនដោយរោងចក្រនុយក្លេអ៊ែរត្រូវរក្សាឲ្យបានកម្រិតទាប ហើយគ្មានបុគ្គលណាមួយត្រូវបានទទួលរងនូវកម្រិតវិទ្យុសកម្មដែលលើសពីការដាក់បញ្ញត្តិពីកម្រិតកំណត់ថ្នាក់ជាតិឡើយ ។

## មាត្រា១៦. ការត្រៀមទុកក្នុងករណីបន្ទាន់

១.បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា ឲ្យមានផែនការសង្គ្រោះបន្ទាន់នឹងកន្លែង និងឆ្ងាយពីកន្លែងដោយមានការសាកល្បងជាប់ជាប្រចាំ សម្រាប់រោងចក្រនុយក្លេអ៊ែរ និងគ្របដណ្តប់នូវ រាល់សកម្មភាពដែលត្រូវអនុវត្តក្នុងគ្រាអាសន្ន ។

២.បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា ពេលដែលពួកគេទំនងជាទទួលរងនូវគ្រោះថ្នាក់ដោយវិទ្យុសកម្ម ប្រជាពលរដ្ឋរបស់ខ្លួន និងអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋដែលនៅជិតរោងចក្រនុយក្លេអ៊ែរ ត្រូវបានគេផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវដើម្បីឆ្លើយតប និងមានផែនការសង្គ្រោះបន្ទាន់។

៣.បណ្តាភាគីជាប់កិច្ចសន្យា ដែលគ្មានរោងចក្រនុយក្លេអ៊ែរនៅលើទឹកដីរបស់ខ្លួន ពេលដែលពួកគេទំនងជាទទួលរងនូវគ្រោះថ្នាក់ដោយវិទ្យុសកម្មពីរោងចក្រនុយក្លេអ៊ែរដែលនៅជិតខាង ត្រូវចាត់វិធានការឲ្យបានសមរម្យដើម្បីត្រៀមទុក និងសាកល្បងផែនការសង្គ្រោះបន្ទាន់ក្នុងដែនដីរបស់ខ្លួន ដែលគ្របដណ្តប់ដោយសកម្មភាព ក្នុងគ្រាអាសន្ន ។

### (ឃ) សុវត្ថិភាព ក្នុងការដំឡើង

## មាត្រា១៧. ការផ្តល់ទីតាំង

បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា នីតិវិធីសមរម្យត្រូវបានគេបង្កើត និងអនុវត្តៈ

(១) វាយតម្លៃកត្តាពាក់ព័ន្ធ និងទីកន្លែងដែលប្រហែលជាប៉ះពាល់នឹងសុវត្ថិភាព នៃដំណើរការរបស់រោងចក្រនុយក្លេអ៊ែរ ។

(២) វាយតម្លៃពីផលប៉ះពាល់នូវសុវត្ថិភាពលើ បុគ្គល សង្គម និង បរិស្ថាន ដោយសាររោងចក្រនុយក្លេអ៊ែរ ដែលបានស្នើសុំ ។

(៣)វាយតម្លៃសារជាថ្មីពីកត្តាពាក់ព័ន្ធ និងចាំបាច់ទាំងអស់ដូចមានចែងក្នុងវាក្យខណ្ឌ (១) និង (២) ដើម្បីធ្វើឲ្យប្រាកដថា ការទទួលយកបាននូវសុវត្ថិភាពនៃរោងចក្រនុយក្លេអ៊ែរ ។

(៤)ពិគ្រោះពិភាក្សា និងបណ្តាភាគីជាប់កិច្ចសន្យាដែលនៅជិតរោងចក្រនុយក្លេអ៊ែរ ពេលដែលពួកគេទំនងជាប៉ះពាល់ ដោយរោងចក្រនោះពេលដែលការស្នើសុំត្រូវផ្តល់ព័ត៌មានចាំបាច់ទៅភាគីជាប់កិច្ចសន្យាដើម្បីអាចឲ្យពួកគេធ្វើការវាយតម្លៃ និងធ្វើការប៉ាន់ប្រមាណដោយខ្លួនគេ ដូចជាផលប៉ះពាល់សុវត្ថិភាពក្នុងទឹកដីរបស់គេពីរោងចក្រនុយក្លេអ៊ែរនោះ ។

**មាត្រា១៨. ការរៀបចំ និង ការសាងសង់**

បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យដើម្បីធ្វើឲ្យប្រាកដថា៖

(១) ការរៀបចំ និងការសាងសង់ នៃរោងចក្រនុយក្លេអ៊ែរ ត្រូវផ្តល់ជូននូវកម្រិតដែលអាចឲ្យជឿទុកចិត្តបានច្រើន និងរបៀបនៃការការពារឲ្យបានរឹងមាំ ទប់ទល់នឹងការលេចធ្លាយវិទ្យុសកម្ម ដោយការពារការកើតឡើងគ្រោះមហន្តរាយ និងដើម្បីកាត់បន្ថយផលវិបាកវិទ្យុសកម្មប្រសិនបើមានការកើតឡើង ។

(២)បច្ចេកវិទ្យាដែលបានរៀបចំ និងសាងសង់រោងចក្រនុយក្លេអ៊ែរ ត្រូវតែបង្ហាញពីបទពិសោធ ឬ គុណភាពដោយការសាកល្បង ឬ ការវិភាគ ។

(៣)ការរៀបចំរោងចក្រនុយក្លេអ៊ែរ ត្រូវធ្វើឲ្យមានការជឿទុកចិត្តបាន ស្ថិរភាព និងប្រតិបត្តិការចាត់ចែង ឲ្យបានងាយស្រួល ដោយមានការពិចារណាច្បាស់លាស់លើកត្តាមនុស្ស និងការពាក់ព័ន្ធគ្រឿងម៉ាស៊ីន ។

**មាត្រា១៩. ប្រតិបត្តិការ**

បណ្តាភាគីជាប់កិច្ចសន្យា ត្រូវចាត់វិធានការឲ្យបានសមរម្យ ដើម្បីធ្វើឲ្យប្រាកដថា

(១)សិទ្ធិអំណាចដំបូង ដើម្បីប្រតិបត្តិការរោងចក្រនុយក្លេអ៊ែរ គឺផ្អែកលើការវិភាគសុវត្ថិភាពសមរម្យ និងការប្រព្រឹត្តទៅនូវកម្មវិធីដើម្បីបង្ហាញឲ្យឃើញថា ការដំឡើងដូចដែលបានសាងសង់ គឺដូចគ្នានឹងការរៀបចំទុក និងតម្រូវការសុវត្ថិភាព។

(២)ល័ក្ខខ័ណ្ឌ និងការកំណត់ប្រតិបត្តិការ ត្រូវយកតាមពីការវិភាគសុវត្ថិភាព ការសាកល្បង និងបទពិសោធប្រតិបត្តិការ ត្រូវបានគេកំណត់យ៉ាងច្បាស់ និងត្រូវបានគេកែប្រែ បើចាំបាច់ដើម្បីកំណត់ព្រំដែនសុវត្ថិភាព សម្រាប់ប្រតិបត្តិការ ។

(៣)ប្រតិបត្តិការ ការថែទាំ ការត្រួតពិនិត្យ និងការសាកល្បង នៃរោងចក្រនុយក្លេអ៊ែរ ត្រូវបានធ្វើឡើងស្របតាម នីតិវិធី ។

(៤)នីតិវិធីត្រូវបានគេបង្កើតឡើង សម្រាប់ការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ។

(៥) ការផ្តល់បច្ចេកទេស និងវិស្វកម្មចាំបាច់ ក្នុងវិស័យដែលទាក់ទិននឹងសុវត្ថិភាព គឺត្រូវតែមានក្នុងដំណើរការ រោងចក្រនុយក្លេអ៊ែរ ។

(៦) ឧប្បត្តិហេតុទៅនឹងសុវត្ថិភាព ត្រូវរាយការណ៍ឲ្យបានទាន់ពេលវេលា ដោយអ្នកកាន់កាប់អាជ្ញាប័ណ្ណដែលពាក់ព័ន្ធ ជូនទៅគណៈកម្មការនិយ័តកម្ម ។

(៧) កម្មវិធី ដែលប្រមូលបាន និងវិភាគប្រតិបត្តិការ បទពិសោធត្រូវបង្កើតឡើង លទ្ធផលដែលទទួលបាន និងការសន្និដ្ឋានត្រូវគូសបញ្ជាក់នឹងធ្វើឡើង ហើយយន្តការដែលមានស្រាប់ត្រូវប្រើ ដើម្បីចែករំលែកបទពិសោធសំខាន់ៗ ជាមួយគណៈកម្មការអន្តរជាតិ អង្គការប្រតិបត្តិការដទៃទៀត និងគណៈកម្មការនិយ័តកម្ម ។

(៨) អាយុកាលនៃកាកសំណល់វិទ្យុសកម្មចេញមកពីប្រតិបត្តិការរោងចក្រនុយក្លេអ៊ែរ ត្រូវរក្សាឲ្យមានកម្រិតទាបបំផុតសម្រាប់ដំណើរការដែលពាក់ព័ន្ធ ទាំងក្នុងសកម្មភាព និងបរិមាណ ។ ការប្រើប្រាស់ និង ការស្តុកទុក ទាំងកាកសំណល់ និងឥន្ធនៈ ដែលទាក់ទងផ្ទាល់នឹងប្រតិបត្តិការក្នុងកន្លែងតែមួយដែលមានរោងចក្រនុយក្លេអ៊ែរ ត្រូវពិចារណាតាមល័ក្ខខ័ណ្ឌ និងការបំផ្លាញចោល។

## ជំពូក៣. ការជួបប្រជុំភាគីជាប់កិច្ចសន្យា

### មាត្រា២០. រំលឹកការប្រជុំឡើងវិញ

១.បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់នឹងជួបប្រជុំ (ហៅកាត់ថា "រំលឹកការប្រជុំឡើងវិញ") ក្នុងបំណងរំលឹកឡើងវិញនូវរាល់របាយការណ៍ដែលបានដាក់ជូន អនុលោមតាម មាត្រា៥ យោងតាមនីតិវិធីដែលបានអនុម័ត ស្ថិតក្រោមមាត្រា២២ ។

២.ប្រធានបទក្នុងបញ្ញត្តិក្នុងមាត្រា២៤ អនុក្រុមរួមមានតំណាងមកពីភាគីជាប់កិច្ចសន្យានឹងអាចត្រូវបានគេបង្កើត និងដើរតួនាទីអំឡុងពេលពិនិត្យឡើងវិញ ការប្រជុំដែលចាត់ទុកថាជាការចាំបាច់ក្នុងគោលបំណងត្រួតពិនិត្យយ៉ាងជាក់លាក់ នូវប្រធានបទដែលមានក្នុងរបាយការណ៍ ។

៣.បណ្តាភាគីជាប់កិច្ចសន្យា ត្រូវមានឱកាសសមស្រប ដើម្បីពិភាក្សារបាយការណ៍ដែលបានដាក់ជូនភាគីជាប់កិច្ចសន្យាដទៃទៀត និងស្វែងរកការបញ្ជាក់នូវរបាយការណ៍នោះ ។

### មាត្រា២១. កាលវិភាគ

១.ការត្រៀមរៀបចំកិច្ចប្រជុំនឹងត្រូវប្រព្រឹត្តឡើង មិនឲ្យលើសពី រយៈពេល ៦ខែ បន្ទាប់ពីថ្ងៃ ចូលជាធរមាន នៃអនុសញ្ញានេះ។

២.នៅពេលរៀបចំកិច្ចប្រជុំ បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ ត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការប្រជុំត្រួតពិនិត្យសារឡើងវិញជាលើកដំបូង។ កិច្ចប្រជុំត្រួតពិនិត្យសារឡើងវិញនេះនឹងត្រូវបានប្រព្រឹត្តធ្វើឡើងឲ្យបានលឿន តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនឲ្យលើសពី៣០ខែ បន្ទាប់ពីថ្ងៃចូលជាធរមាននៃអនុសញ្ញានេះ ។

៣.នៅពេលប្រជុំត្រួតពិនិត្យសារឡើងវិញម្តងៗ បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ ត្រូវកំណត់កាលបរិច្ឆេទ សម្រាប់ការប្រជុំបន្ទាប់ ។ ចន្លោះពេល រវាងកិច្ចប្រជុំត្រួតពិនិត្យសារជាថ្មីឡើងវិញ នឹងមិនឲ្យលើសពីរយៈពេល៣ឆ្នាំ ។

### មាត្រា២២. របៀបរៀបចំនីតិវិធី

១.ការត្រៀមរៀបចំកិច្ចប្រជុំនឹងត្រូវប្រព្រឹត្តឡើងអនុលោមតាមមាត្រា២១ បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ ត្រូវរៀបចំ និងអនុម័តដោយមតិឯកច្ឆ័ន្ទនូវបញ្ញត្តិនៃនីតិវិធី និងបញ្ញត្តិហិរញ្ញវត្ថុ ។ បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ ត្រូវបង្កើតបញ្ញត្តិពិសេសយោងតាមនីតិវិធីច្បាប់។

(១) គោលការណ៍ណែនាំចំពោះបែបបទ និង រចនាសម្ព័ន្ធ នៃរបាយការណ៍ ដែលត្រូវបានដាក់ជូន អនុលោមតាមមាត្រា៥ ។

(២) កាលបរិច្ឆេទការដាក់ជូនរបាយការណ៍ ។

(៣) ដំណើរការត្រួតពិនិត្យសារឡើងវិញនូវរបាយការណ៍ ។

២.កិច្ចប្រជុំត្រួតពិនិត្យសារឡើងវិញ បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ ប្រសិនបើចាំបាច់ អាចពិនិត្យឡើងវិញ នូវរបៀបបង្កើតឡើងដោយអនុលោមតាមវាក្យខណ្ឌ(១)-(៣) ខាងលើ និងអនុម័តការកែប្រែ ដោយមតិឯកច្ឆន្ទប្រសិនបើមិនបានផ្តល់នូវបញ្ញត្តិស្របតាមនីតិវិធីច្បាប់។ គេអាចធ្វើវិសោធនកម្មបានផងដែរ នូវបញ្ញត្តិនីតិវិធី និងបញ្ញត្តិហិរញ្ញវត្ថុ ដោយមតិឯកច្ឆន្ទ។

### មាត្រា២៣. ការប្រជុំវិសាមញ្ញ

ការប្រជុំវិសាមញ្ញមួយ នៃបណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ ត្រូវប្រព្រឹត្តឡើង៖

(១) ប្រសិនបើត្រូវបានគេយល់ព្រមដោយមតិភាគច្រើនដាច់ខាតនៃបណ្តាភាគីជាប់កិច្ចសន្យាដែលមានវត្តមាន និង

បោះឆ្នោតក្នុងសម័យប្រជុំនោះ ការបោះឆ្នោតអនុប្បវាទ ត្រូវបានគេចាត់ទុកថាជាការបោះឆ្នោតដែរ

(២) តាមសំណើស្នើសុំជាលាយល័ក្ខណ៍អក្សររបស់ភាគីជាប់កិច្ចសន្យាមួយក្នុងរយៈពេល ០៦ខែ នៃសំណើនេះ ត្រូវបានគេទាក់ទងទៅបណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ និងការជូនដំណឹងដែលបានទទួលដោយលេខាធិការដ្ឋានដូចមានចែងក្នុងមាត្រា២៨ តាមសំណើដែលបានគាំទ្រដោយមតិភាគច្រើនរបស់បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់នោះ ។

**មាត្រា២៤. ការចូលរួមប្រជុំ**

១.ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវចូលរួមកិច្ចប្រជុំនៃភាគីជាប់កិច្ចសន្យា និងត្រូវមានវត្តមានក្នុងកិច្ចប្រជុំនោះ តំណាងដោយប្រតិភូ១រូប ដោយផ្លាស់ប្តូរគ្នា ដូចជា អ្នកជំនាញ និងទីប្រឹក្សា បើចាត់ទុកជាករណីចាំបាច់ ។

២.បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ អាចធ្វើការអញ្ជើញដោយមតិឯកច្ឆន្ទដល់អង្គការអន្តររដ្ឋាភិបាលណាមួយដែលមានសមត្ថកិច្ចគ្រប់គ្រងដោយអនុសញ្ញានេះដើម្បីចូលរួម ឬ ធ្វើអ្នកសង្កេតការណ៍រាល់ការប្រជុំ ឬ សម័យប្រជុំជាក់លាក់ណាមួយ។ អ្នកសង្កេតការណ៍ទាំងអស់នឹងតម្រូវឲ្យយល់ព្រមទទួលជាលាយល័ក្ខណ៍អក្សរ នៅមុនពេលប្រជុំ ស្របតាមមាត្រា២៧ ។

**មាត្រា២៥. របាយការណ៍សង្ខេប**

បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ត្រូវអនុម័ត ជាឯកច្ឆន្ទនឹងធ្វើឲ្យមានប្រយោជន៍ជាសាធារណៈនូវឯកសារ ដែលត្រូវបានពិភាក្សាដោះស្រាយបញ្ហា និងសេចក្តីសន្និដ្ឋាន ដែលបានអនុម័តក្នុងពេលប្រជុំ ។

**មាត្រា២៦. ភាសា**

១.ភាសាក្នុងកិច្ចប្រជុំនៃភាគីជាប់កិច្ចសន្យារួមមាន ភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងភាសាអេស្ប៉ាញប្រសិនបើមិនបានផ្តល់ក្នុងបញ្ញត្តិនៃនីតិវិធី ។

២.របាយការណ៍ដែលបានដាក់ជូនអនុលោមតាមមាត្រា៥ ត្រូវបានគេរៀបចំជាភាសាជាតិ សម្រាប់ដាក់ជូនភាគីជាប់កិច្ចសន្យា ឬ ក៏ជាភាសាតែមួយដែលត្រូវបានឯកភាពក្នុងបញ្ញត្តិនៃនីតិវិធី ។ ប្រសិនបើរបាយការណ៍ដែលត្រូវបានគេដាក់ជូនជាភាសាជាតិ ជាភាសាដែលគេបានកំណត់ ការបកប្រែរបាយការណ៍ទៅជាភាសាមួយដែលគេបានកំណត់ដែលផ្តល់ដោយភាគីជាប់កិច្ចសន្យា ។

៣.ថ្វីបើមានល័ក្ខខ័ណ្ឌនៃកថាខណ្ឌ២ ប្រសិនបើចង់កែប្រែ លេខាធិការដ្ឋាននឹងទទួលយកការបកប្រែជាភាសា ដែលគេបានកំណត់សម្រាប់របាយការណ៍ដែលត្រូវដាក់ជូនក្នុងកិច្ចប្រជុំ។

**មាត្រា២៧. ការសម្ងាត់**

១.បញ្ញត្តិនៃអនុសញ្ញានេះនឹងមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ច នៃភាគីជាប់កិច្ចសន្យាស្ថិតក្រោមច្បាប់របស់គេដើម្បីការពារព័ត៌មានពីការបែកការសម្ងាត់ ។ សម្រាប់គោលបំណងនៃមាត្រានេះ " ព័ត៌មាន" រួមទាំង ព័ត៌មានដទៃទៀត(១) ទិន្នន័យផ្ទាល់ខ្លួន(២) ព័ត៌មានដែលត្រូវការពារដោយសិទ្ធិបញ្ញា ឬដោយជំនឿទុកចិត្តខាងពាណិជ្ជកម្ម និងឧស្សាហកម្ម (៣) ព័ត៌មានទាក់ទងនឹងសន្តិសុខជាតិឬ ការការពាររូបវន្តវត្ថុធាតុនុយក្លេអ៊ែរ ឬ រោងចក្រនុយក្លេអ៊ែរ។

២.បរិបទនៃអនុសញ្ញានេះ ពេលភាគីជាប់កិច្ចសន្យាផ្តល់ព័ត៌មាន ដែលកំណត់ការពារដូចចែង ក្នុងកថាខ័ណ្ឌ១ ដូចនេះព័ត៌មាននោះត្រូវបានគេប្រើសម្រាប់គោលបំណងគោរពនិងជាការសម្ងាត់ ។

៣.មាតិកានៃការពិភាក្សាអំឡុងពេលការត្រួតពិនិត្យសារឡើងវិញនូវរបាយការណ៍ដោយបណ្តាភាគីជាប់កិច្ចសន្យាក្នុងកិច្ចប្រជុំនីមួយៗត្រូវតែចាត់ទុកជាការសម្ងាត់ ។

**មាត្រា២៨. លេខាធិការដ្ឋាន**

១.ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (ហៅកាត់ថា " ទីភ្នាក់ងារ") នឹងផ្តល់លេខាធិការដ្ឋាន សម្រាប់កិច្ចប្រជុំភាគីជាប់កិច្ចសន្យាៈ

២.លេខាធិការដ្ឋានត្រូវៈ

(១) កោះប្រជុំ រៀបចំ និងបម្រើដល់ការប្រជុំ នៃបណ្តាភាគីជាប់កិច្ចសន្យាទាំងអស់ ។

(២) បញ្ជូនទៅ ភាគីជាប់កិច្ចសន្យានូវព័ត៌មានដែលទទួលបាន ឬ រៀបចំទុក ដោយយោងតាមបញ្ញត្តិ នៃអនុសញ្ញានេះ ។

ការចំណាយដោយទីភ្នាក់ងារ ក្នុងការអនុវត្តនូវតួនាទីដូចមានចែងក្នុងវាក្យខណ្ឌ(១) និង(២)ខាងលើត្រូវផ្គត់ផ្គង់ដោយទីភ្នាក់ងារដែលជាផ្នែកមួយនៃថវិការបស់ខ្លួន ។

៣. បណ្តាភាគីជាប់កិច្ចសន្យាទាំងអស់អាចស្នើសុំជាឯកច្ឆន្ទទៅទីភ្នាក់ងារដើម្បីផ្តល់សេវាកម្មផ្សេងទៀតក្នុងការគាំទ្រកិច្ចប្រជុំបណ្តាភាគីជាប់កិច្ចសន្យា។ទីភ្នាក់ងារអាចផ្តល់សេវាទាំងនោះប្រសិនបើត្រូវបានគេធ្វើឡើងក្នុងកម្មវិធីនិងថវិការបស់ខ្លួន។ ប្រសិនបើបញ្ហានេះមិនអាចប្រព្រឹត្តទៅរួច ទីភ្នាក់ងារអាចផ្តល់សេវានោះ បើការផ្តល់មូលនិធិស្ម័គ្រចិត្ត ត្រូវបានគេផ្តល់ឲ្យពីប្រភពផ្សេងៗ ។

## ជំពូក៤. បញ្ញត្តិផ្សេងៗ និងអវសានបញ្ញត្តិ

**មាត្រា២៩. ដំណោះស្រាយវិវាទ**

ក្នុងព្រឹត្តការណ៍មានវិវាទ រវាងភាគីជាប់កិច្ចសន្យា២ ឬ ច្រើន ពាក់ព័ន្ធនឹងការបកប្រែ ឬ ការអនុវត្ត នៃអនុសញ្ញានេះ ភាគីជាប់កិច្ចសន្យាត្រូវពិភាក្សាក្នុងវង្វង់នៃកិច្ចប្រជុំភាគីជាប់កិច្ចសន្យា ដើម្បីធ្វើការដោះស្រាយនូវវិវាទនោះ ។

**មាត្រា៣០. ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ការយល់ព្រម**

១.អនុសញ្ញានេះត្រូវបើកឲ្យចុះហត្ថលេខាដោយបណ្តារដ្ឋទាំងឡាយ នៅឯស្នាក់ការកណ្តាលនៃទីភ្នាក់ងារ នាទីក្រុង វីយែន (Vienna ) ពីថ្ងៃទី ២០ ខែ សីហា ១៩៩៤ រហូតចូលជាធរមាន ។

២.អនុសញ្ញានេះជាប្រធានបទនៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តដោយរដ្ឋហត្ថលេខី ទាំងអស់ ។

៣.បន្ទាប់ពីការចូលជាធរមាន អនុសញ្ញានេះនឹងបើកឲ្យមានការយល់ព្រមពីបណ្តារដ្ឋទាំងអស់ ។

៤.(១) អនុសញ្ញានេះនឹង ត្រូវបានបើកឲ្យចុះហត្ថលេខា ឬ យល់ព្រមដោយអង្គការនានាក្នុងការធ្វើសមាហរណកម្ម ឲ្យតែអង្គការនោះស្ថិតក្នុងរដ្ឋអធិបតេយ្យ និងមានសមត្ថកិច្ចក្នុងការចរចា ការសម្រេច និងការអនុវត្តនៃកិច្ចព្រមព្រៀងអន្តរជាតិដែលបានគ្របដណ្តប់ដោយអនុសញ្ញានេះ ។

(២) រាល់បញ្ហាក្នុងដែនសមត្ថកិច្ចក្នុងអង្គការនោះ ក្នុងនាមខ្លួនផ្ទាល់ត្រូវធ្វើការិយកម្មសិទ្ធិ និងបំពេញភាពទទួលខុសត្រូវដូចដែលអនុសញ្ញានេះបានកំណត់ដល់រដ្ឋភាគីទាំងអស់ ។

(៣) ពេលដែលក្លាយជាភាគីនៃអនុសញ្ញានេះ អង្គការនោះត្រូវទំនាក់ទំនងទៅអ្នកទទួលបញ្ញើ (Depositary) យោងតាមមាត្រា៣៤ ដើម្បីប្រកាសបង្ហាញឲ្យឃើញថា រដ្ឋទាំងនោះជាសមាជិកដែលមាត្រាទាំងឡាយនៃអនុសញ្ញានេះបានតម្រូវ ហើយវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួនក្នុងវិស័យនេះត្រូវបានគ្របដណ្តប់ក្នុងគ្រប់មាត្រាទាំងអស់នោះរួចហើយឲ្យអនុវត្ត ។

(៤) អង្គការនោះមិនត្រូវបោះឆ្នោតថែមទៀតជូនរដ្ឋ ដែលជាសមាជិកទាំងអស់របស់ខ្លួនឡើយ។

៥. លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័តឬ ការយល់ព្រម ត្រូវបានដាក់តម្កល់ទុកនៅអ្នកទទួលបញ្ញើ (Depositary) ។

**មាត្រា៣១. ការចូលជាធរមាន**

១.អនុសញ្ញានេះនឹងចូលជាធរមានរយៈពេល ៩០ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់តម្កល់ទុកនៅអ្នកទទួលបញ្ញើ(Depositary) នៃលិខិតូបករណ៍ទី ២២ នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័ត រួមទាំងលិខិតូបករណ៍នៃរដ្ឋទាំង១៧ ដោយយ៉ាងហោចណាស់ប្រទេសនីមួយៗមានផាងចក្រនុយក្លេអ៊ែរ ដែលបានសម្រេចជាគជ័យយ៉ាងធំធេង ក្នុងវិស័យថាមពលនុយក្លេអ៊ែរ។

២.សម្រាប់រដ្ឋ ឬ អង្គការតំបន់នីមួយៗ នៃសមាហរណកម្មដែលបានផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬយល់ព្រមនឹងអនុសញ្ញានេះបន្ទាប់ពីថ្ងៃបានដាក់លិខិតូបករណ៍ចុងក្រោយដើម្បីបំពេញល័ក្ខខ័ណ្ឌដែលបានពន្យល់ក្នុងកថាខ័ណ្ឌ១ អនុសញ្ញានេះនឹងចូលជាធរមានរយៈពេល ៩០ថ្ងៃបន្ទាប់ពីថ្ងៃដាក់នៅអ្នកទទួលបញ្ញើ(Depositary) នូវលិខិតតូបករណ៍ឲ្យសមរម្យ ដោយរដ្ឋ ឬ អង្គការនោះ ។

**មាត្រា៣២. ការធ្វើវិសោធនកម្មលើអនុសញ្ញា**

១.បណ្តាភាគីជាប់កិច្ចសន្យាអាចស្នើសុំធ្វើវិសោធនកម្មលើអនុសញ្ញានេះ។ វិសោធនកម្មដែលត្រូវបានស្នើសុំនឹងត្រូវបានគេពិចារណានៅឯកិច្ចប្រជុំត្រួតពិនិត្យសារឡើងវិញ ឬ កិច្ចប្រជុំវិសាមញ្ញ។

២.អត្ថបទ នៃវិសោធនកម្មដែលបានស្នើសុំ និងហេតុផលនឹងត្រូវគេផ្តល់ទៅអ្នកទទួលបញ្ញើ( Depositary ) ដែលនឹងផ្សព្វផ្សាយ សំណើទៅ ភាគីជាប់កិច្ចសន្យាភ្លាមៗ យ៉ាងហោចណាស់ ៩០ថ្ងៃមុនពេលកិច្ចប្រជុំដើម្បីដាក់ឲ្យធ្វើការពិចារណា។ យោបល់ដែលបានទទួលលើសំណើនោះនឹងត្រូវបានផ្សព្វផ្សាយដោយអ្នកទទួលបញ្ញើ ( Depositary ) ទៅកាន់ភាគីជាប់កិច្ចសន្យា។

៣.ភាគីជាប់កិច្ចសន្យានឹងសម្រេចចិត្តបន្ទាប់ពីការពិចារណានៃវិសោធនកម្មដែលបានស្នើសុំនេះ ថាតើត្រូវអនុម័តដោយមតិឯកច្ឆន្ទ ឬ ដោយគ្មានមតិឯកច្ឆន្ទ ដើម្បីដាក់ជូនសន្និសីទការទូត។ សេចក្តីសម្រេចចិត្តដាក់វិសោធនកម្មដែលបានស្នើសុំជូនសន្និសីទការទូតនឹងតម្រូវឲ្យការបោះឆ្នោតយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាត ២ភាគ៣ នៃបណ្តាភាគីជាប់កិច្ចសន្យាដែលមានវត្តមានក្នុងកិច្ចប្រជុំនោះ យ៉ាងហោចណាស់ចំនួនពាក់កណ្តាល នៃបណ្តាភាគីជាប់កិច្ចសន្យាដែលមានវត្តមានក្នុងពេលបោះឆ្នោតនោះ ។ ការបោះឆ្នោតអនុប្បវាទត្រូវចាត់ទុកថាជាការបោះឆ្នោតដែរ ។

2. The Depositary shall inform the Contracting Parties of:

(i) the signature of this Convention and of the deposit of instruments of ratification, acceptance, approval or accession, in accordance with Article 30;

(ii) the date on which the Convention enters into force, in accordance with Article 31;

(iii) the notifications of denunciation of the Convention and the date thereof, made in accordance with Article 33;

(iv) the proposed amendments to this Convention submitted by Contracting Parties, the amendments adopted by the relevant Diplomatic Conference or by the meeting of the Contracting Parties, and the date of entry into force of the said amendments, in accordance with Article 32.

ARTICLE 35. AUTHENTIC TEXTS

The original of this Convention of which the Arabic, Chinese, English, French, Russian and Spanish texts are equally authentic, shall be deposited with the Depositary, who shall send certified copies thereof to the Contracting Parties.

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៤៥

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រតនត្ដយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ដោយរក្សាមុខតំណែងជាអ្នកនយោបាយ ៖

១-ឯកឧត្ដម **វ៉ាន់ វ៉ាន** ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្ដិឧត្ដមមន្ត្រីថ្នាក់លេខ៣ ចាប់ពីថ្ងៃទី **០១ ខែ កុម្ភៈ ឆ្នាំ ២០១៣**
២-ឯកឧត្ដម **មាស រ៉េន** ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្ដិឧត្ដមមន្ត្រីថ្នាក់លេខ៣ ចាប់ពីថ្ងៃទី **០១ ខែ កក្កដា ឆ្នាំ ២០១៣**
៣-ឯកឧត្ដម **បាន ណុន** ចូលនិវត្តន៍ ក្នុងឋានន្តរស័ក្ដិឧត្ដមមន្ត្រីថ្នាក់លេខ៦ ចាប់ពីថ្ងៃទី **០១ ខែ កញ្ញា ឆ្នាំ ២០១៣**

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

ចារចោ.១៣០១.០៤៥

លេខ ៣១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងជាសមាជិកបន្ថែមនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ៖

១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ខៀវ ថវិកា** ទីប្រឹក្សារាជរដ្ឋាភិបាល
២-ឯកឧត្តមបណ្ឌិត **សុខ ទូច** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
៣-ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី** ប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា
៤-ឯកឧត្តមបណ្ឌិត **អ៊ាច បុណ្ណារ** ប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃរាជបណ្ឌិត្យសភាកម្ពុជា
៥-ឯកឧត្តម **ផៃ ស៊ុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់
៦-លោកបណ្ឌិត **លី ស្មី** មន្ត្រីខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
៧-លោកបណ្ឌិត **ឆោ ឈុនណារិទ្ធ** មន្ត្រីខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
៨-លោកបណ្ឌិត **សួន ឱសថ** ជំនាញភាសាខ្មែរ បាឡី និងសំស្រ្កឹត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ២ :** អនុញ្ញាតឲ្យឯកឧត្តម **ឡាយ សុខា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ លាឈប់ពីសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ និង តែងតាំងលោក **ឡាយ ម៉ុនថន** តំណាងក្រសួងមហាផ្ទៃ ជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរជំនួស។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

៧៣៤.១៣០១.០២៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣*

លេខៈ ៧៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**ឡាយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០២៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ចំនួន ០៣រូប ដែលមានស្នាដៃល្អ
និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- លោកជំទាវវេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី**

២- លោកជំទាវ **ច័ន្ទ សូរីយ៍**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** និង **មហាសេនា** :

- លោកជំទាវ **ញៀម មរកត**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៥.១៣០១.០២៩

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៣

លេខៈ ៣០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/ ០៧៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៣០រូប ដែលបានបំពេញភារកិច្ចយ៉ាងមមាញឹកនិងសម្រេចបានជោគជ័យក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី២០ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៤៥ កិច្ចប្រជុំកំពូលអាស៊ានលើកទី២១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធក្នុងឆ្នាំ ២០១២ កន្លងទៅ

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍:**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ឡុង | វិសាលោ | ៥-លោកជំទាវ | សៀង | វឌ្ឍនាវី |
| ២-ឯកឧត្តម | អ៊ុង | ស៊ាន | ៦-ឯកឧត្តម | សុក | ស៊ីផាន់ណា |
| ៣-ឯកឧត្តម | កៅ | គីមហួន | ៧-ឯកឧត្តម | មាស | គីមហេង |
| ៤-លោកជំទាវ | ស៊ុន | សារឿន | | | |

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា:**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | កុយ | កួង | ៤-ឯកឧត្តម | ជុំ | សុន្ទរី |
| ២-ឯកឧត្តម | ហ៊ុល | ផានី | ៥-ឯកឧត្តម | ថៃ | វណ្ណា |
| ៣-ឯកឧត្តម | កាន់ | ផារិទ្ធ | ៦-ឯកឧត្តម | សៀង | ប៊ុនធុន |

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | តូច | កែម៉ារី | ១០-លោក | មាស | សុខសេនសាន |
| ២-ឯកឧត្តម | ជេត | ណារ៉ែន | ១១-លោក | សុក | ដា |
| ៣-លោក | អ៊ុង | រចនា | ១២-លោក | ហួ | សុផារ៉ា |
| ៤-លោក | ខួន | ស៊ីវត្ថា | ១៣-លោក | អ៊ុក | តាង |
| ៥-លោក | កែវ | វិសិដ្ឋ | ១៤-លោក | ផន | ពៅ |
| ៦-លោក | ប្រាក់ | ខួនហុង | ១៥-លោក | ផូ | សំអាង |
| ៧-លោក | គីន | វិជ្ជាវឌ្ឍនា | ១៦-លោក | ពេជ្រ | ឃុនបញ្ញា |
| ៨-លោក | ស៊ឹម | សុខុម | ១៧-លោក | អ៊ឹម | ហេន |
| ៩-លោកស្រី | ជា | គីមថា | | | |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

០៧៩-១៣០១.០៧៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣*

[illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៣
[illegible] រដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

## ចំពោះ

មន្ត្រីរាជការចំនួន ១៧៣រូប ដែលមានគុណបំណាច់ និងស្នាដៃឆ្នើមក្នុងការបំរើជាតិ មាតុភូមិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

## នូវ

ក- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់**មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តម **សក់ សេដ្ឋា** ២-ឯកឧត្តម **លូ រ៉ាមីន**
៣-ឯកឧត្តម **លេង វី** ៤-ឯកឧត្តម **ស៊ុន ហេង**
៥-ឯកឧត្តម **ប៊ុត គីមស៊ាន** ៦-ឯកឧត្តម **ខាន់ ម៉ាណោរ**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តម **អង មង្គល** ២-ឯកឧត្តម **រាជ សុគន្ធ**
៣-ឯកឧត្តម **ជា ម៉ុង** ៤-ឯកឧត្តម **លី វ៉ាន់ហុង**
៥-ឯកឧត្តម **លី វ៉ាន់ហុង** ៦-ឯកឧត្តម **ហ៊ុន សុធី**
៧-ឯកឧត្តម **ឌី សុភផាន** ៨-លោកជំទាវ **ឈួន នួច**
៩-លោក **យិន ម៉ាលីណា** ១០-លោក **ប្រាក់ សំអឿន**
១១-លោក **សាំង ប៊ុនថេន** ១២-លោក **អ៊ុន សាវុធ**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់**មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តម **ពេជ្រ វណ្ណា** ២-ឯកឧត្តម **ឆ៊ាង វ៉ាន់ថា**

ROYAUME DU CAMBODGE * LE MINISTRE ... PALAIS ROYAL
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៣-លោកកឧកញ៉ា | ស៊ុយ ជីហ៊ាង | ៤-លោកកឧកញ៉ា | ទេង ស្រ៊ុន |
| ៥-លោក | ឆាយ សុមេធ | ៦-លោក | ចាន់ សំបូរ |

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ថាន់ ចំរើន | ២-ឯកឧត្តម | ឡាយ ទេវាហារិទ្ធ |
| ៣-លោក | ទឹម ដារ៉េត | ៤-លោក | ញឹក ពេជ |
| ៥-លោក | ហួន ម៉ារុន | ៦-លោក | នី គឹមសាន |
| ៧-លោក | អេង ចំនួតារា | ៨-លោក | ជា សួរ |
| ៩-លោក | យឹម សំអុល | ១០-លោក | ហោជិន ទីរយុទ្ធ |
| ១១-លោក | ពេជ្រ កែវមុនី | ១២-លោក | សុខ ចំរើន |
| ១៣-លោក | ឈិន សេងខួន | ១៤-លោក | សូ មុនីរក្សា |
| ១៥-លោក | ដាក សាវី | ១៦-លោក | ស៊ី ថារិន |
| ១៧-លោក | ញៀម សារី | ១៨-លោក | ថន ស៊ីផា |
| ១៩-លោក | សុខ ជឿន | ២០-លោក | យ៉ុំ ម៉េងស៊ាន |
| ២១-លោក | ខោល យុទ្ធលី | ២២-លោក | ស្រេង សុភាព |
| ២៣-លោក | កែវ គុជសី | ២៤-លោក | កង ប៊ិន |
| ២៥-លោក | អ៊ុន សុវត្ថា | ២៦-លោក | ម៉ី ណារ៉ាត់ |
| ២៧-លោក | ថា ថាន់ធឿន | ២៨-លោក | ហ៊ូ ណាវុធ |
| ២៩-លោក | ឆាន់ ចន្ទសុភក្ត្តិ | ៣០-លោក | ប្រាក់ ថាន់ណារិទ្ធ |
| ៣១-លោក | ម៉ារុន ម៉ារូណាត | | |

ង- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

| | | | |
|---|---|---|---|
| ១-លោក | ថិន ហួត | ២-លោក | អ៊ុង ប៊ុនហៃល |
| ៣-លោក | ហ្វាន់ គិញ | ៤-លោក | ម៉ៅ សំអឿន |
| ៥-លោក | អ៊ុន សារឿន | ៦-លោក | ម៉ៅ សំអឿន |
| ៧-លោក | ជាប សុខ | ៨-លោក | គុយ រុំ |
| ៩-លោក | គិច គឹមផា | ១០-លោក | ម៉ៅ សាន់សូនា |
| ១១-លោក | ម៉ៅ សាន់សូនា | ១២-លោក | កង ស៊ីថា |
| ១៣-លោក | កង ស៊ីថា | ១៤-លោក | ហង់ ចំនួរិទ្ធ |
| ១៥ -លោក | ឆុំ ប៊ុនណា | ១៦-លោក | ផាយ វណ្ណៈ |
| ១៧-លោក | ផាយ វណ្ណៈ | ១៨-លោក | ច្រឹង សោភ័ណ្ឌ |
| ១៩-លោក | ខុម ថាន់និត | ២០-លោក | អ៊ុន សុខាវុឌ្ឍី |
| ២១-លោក | មោក ស៊ុន | ២២-លោកស្រី | រស់ សុគុណា |

ច- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

| | | | |
|---|---|---|---|
| ១-ឧកឧតម | ហេង សំអាន | ២-លោក | គីវ ហ៊ីន |
| ៣-លោក | ចាប សឿន | | |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | សេង | ហ៊ន់ស៊ី | ២-លោក | ពន្លឺ | មង្គល |
| ៣-លោក | លឹម | គុងហួត | ៤-លោក | យង់ | សុវណ្ណនា |
| ៥-លោក | ចេវ | សារ៉េន | ៦-លោក | ហ៊ុយ | សារុន |
| ៧-លោក | សេក | ចំនួនបុណ្ណ | ៨-លោក | កង | វណ្ណារ៉ូ |
| ៩-លោក | តេង | ប៊ុនធុន | ១០-លោក | សួន | តារា |
| ១១-លោក | ជា | ប៊ុនហេង | ១២-លោក | គុត | ចំនួនប៊ុណ្ណា |
| ១៣-លោក | ព្រួញ | រិទ្ធថា | ១៤-លោក | សួ | ប៊ុណ្ណារ៉ុង |
| ១៥-លោក | លុត | គៀន | ១៦-លោកស្រី | ឡាយ | អូនរី |
| ១៧-លោក | ស្រ៊ុន | កាំងហេង | ១៨-លោក | យិន | វណ្ណៈ |
| ១៩-លោក | នូ | សុវណ្ណារិទ្ធ | ២០-លោក | ប៊ូ | សារឡៅ |
| ២១-លោក | ទិន | ប្រុស | ២២-លោក | ឆាង | វ័យ |
| ២៣-លោក | ថេង | កន្តុំ | ២៤-លោក | លឹម | ឆាយ |
| ២៥-លោក | ឌុច | សុគន្ធ | ២៦-លោក | ឆាយ | អ៊ាន |
| ២៧-លោក | យ៉ែត | ឆឿន | ២៨-លោក | សម | ច្រាថ្លា |

ជ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | អ៊ិន | សុខុម | ២-កញ្ញា | ថាប់ | មុនីជាវណ្ណ |
| ៣-លោក | សល់ | សុនត្ត | ៤-កញ្ញា | វដ្ដា | រ៉ាក់ស៊ា |
| ៥-លោក | ធិន | ម៉ាក់ឆែល | ៦-លោក | សុត | កុសល្យ |
| ៧-លោក | សោម | កុសល | ៨-លោក | មួន | ណារិទ្ធ |
| ៩-លោក | សក់ | ចំនួនកញ្ញារិទ្ធ | ១០-លោក | ម៉ាត់ | គ្រីយ៉ា |
| ១១-លោក | វេជ្ជ | គឹមជុង | ១២-លោក | ណុប | ណូវី |
| ១៣-លោក | កៅ | សុខា | ១៤-លោក | ហេង | វណ្ណី |

ឈ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សប្បទ្ធិ** :

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ញ៉ៅ | ហួង | ២-ឯកឧត្តម | ផាន់ | សុភាព |
| ៣-ឯកឧត្តម | ឱុន | ភក្តី | ៤-លោកជំទាវ | តាំង | ទូចគាង |
| ៥-ឯកឧត្តម | លឹម | ប៊ុនហេង | ៦-លោក | រុន | ចាន់ដារ៉ារិទ្ធ |
| ៧-លោក | ថាច់ | ថារ័ត្ន | ៨-លោក | តូ | លិ |
| ៩-លោកស្រី | ឱិត | ប៊ូលី | ១០-លោកស្រី | ភាប៊ុត | សុមឡា |
| ១១-លោកស្រី | សីរ៉េត | ចំនួនឆវ័ណ្ណ | ១២-លោក | ឡេង | វ៉ាវឌ្យ |
| ១៣-លោក | គឹម | យុទ្ធី | ១៤-លោក | ប៊ុត | ពិសិដ្ឋ |
| ១៥-លោកស្រី | ស៊ុត | ម៉ុ | ១៦-លោក | សាន | សម្បត្តិ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ព្រះបរមរាជវាំង

១៧-លោក សាត គីមសាន

១៨-លោក គុយ សុខ

១៩-លោកស្រី ស៊ុខ សុខុន

២០-លោក ម៉េង អ៊ីច

២១-លោក យ៉ា សុផាត

២២-លោក ឡុច សាលឿម

២៣-លោក ហាច ហ៊ាន

២៤-លោក ហេង ប៊ុនលី

២៥-លោក ស៊ិន សនឈិន្លៀង

២៦-លោក អេង ណាង

២៧-លោក ជួង សុត្ថា

២៨-លោក ឆាយ ណូ

២៩-លោក យ៉ុំ គីមសេង

៣០-លោក ផេង សារុំ

៣១-លោក គីម ចិន្ដា

៣២-លោក យិន សុពល

៣៣-លោក ហេង សូលីឌីន

៣៤-លោក គី រតនា

៣៥-លោក ឆូ សាន

៣៦-លោក ទ៉ែត ចាន់ធី

៣៧-លោក តេ សាន

៣៨-លោក ផាន់ រតនា

៣៩-លោក សុខ សុទ្ធី

៤០-កញ្ញា ហេង សុជាតា

៤១-លោក ស៊ិត សូលីដា

៤២-លោក អេង សាលឿន

៤៣-លោក ហេង សុផាត

៤៤-លោក ស៊ុន ឈុនហៀង

៤៥-កញ្ញា អ៊ាម ចាន់សោភា

៤៦-លោក ពិ ធីរ៉ា

៤៧-លោក សូ សុខា

៤៨-លោកស្រី ភាក់ សោភា

៤៩-លោក សរ សារី

៥០-លោក ផុង សារិន

៥១-លោក នួន សម្បត្តិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៧៧៤.១៣០១.០៣០*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣*

លេខៈ ២៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ២០១៣

**អគ្គលេខាធិការគណៈរាជរដ្ឋាភិបាល**

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ**

ចំពោះ

ឯកឧត្តម **សែម គីថាយ**

ដែលបានខិតខំបំពេញភារកិច្ចជូនជាតិមាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៨៣.១៣០១.០៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៣

លេខៈ ៣៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៣៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

**ជូន**

## គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

**លោកជំទាវ ឧកញ៉ា ជា ណែត**

ដែលមានគុណបំណាច់ និងស្នាដៃល្អជាច្រើន ក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ
ដោយបានទិញរថយន្តសង្គ្រោះចំនួន០១គ្រឿង សម្រាប់មណ្ឌលសុខភាព ស្រុកព្រែកប្រសព្វ ហើយគ្រោងនឹងសាងសង់
អនុវិទ្យាល័យ ០១ខ្នង នៅភូមិដីដុះ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ បន្ថែមទៀត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣៩៤-១៣០១-០៣៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

លេខៈ ៥៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការគណៈរដ្ឋមន្ត្រីទទួលបន្ទុករាជរដ្ឋាភិបាល

[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៣៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ពុំទទួលប្រាក់បៀវត្ស៍ :

១- ឯកឧត្តម **សរ ចំរុង**

២- ឯកឧត្តម **កែន សត្ថា**

៣- ឯកឧត្តម **ហង្ស សាមឿន**

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស.១៣០១.០៣៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

លេខៈ ៣៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៣៧៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិឯកឧត្តម **ស្រី សួន** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១ ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៥៨-១៣០១-០៣៧៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

លេខ ...៤ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០១៣
[illegible] រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៣៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ចំពោះ

លោកបណ្ឌិត LAlith Goonatilake

នាយកផ្នែកកសាងសមត្ថភាពពាណិជ្ជកម្ម នៃអង្គការ UNIDO
ដែលមានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
ដោយបានជួយកសាងសមិទ្ធផលជាច្រើនលើវិស័យឧស្សាហកម្ម ស្តង់ដារ និងមាត្រាសាស្ត្រ
រួមចំណែកក្នុងការកសាងប្រទេសកម្ពុជា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៣០១.០៣៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

លេខៈ ៤៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជននិងមន្ត្រីរាជការ ចំនួន៥៦ រូប មានស្នាដៃល្អក្នុងការចូលរួម
ជួយកសាងសមិទ្ធផលនានា នៅភូមិ ឃុំមួយចំនួន ក្នុងខេត្តព្រះសីហនុ

នូវ

ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍

១- លោក ចេង គឹមហេង
២- លោក ឆៃ ផាន
៣- លោកស្រី ប្រាក់ ច័ន្ទសុខា
៤- ឧកញ៉ា តែ តាំងប៉
៥- លោកស្រី ទីម គឹមហ៊ាង

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម ជាម កោសេន
២- លោក ជា នាង

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

១- លោកស្រី ម៉ា ស៊ីផន
២- លោក ឈុន ប៊ុនថា
៣- ព្រះតេជគុណ ញ៉ូង ឆៃ
៤- ព្រះតេជគុណ ជន ជុន
៥- ព្រះតេជគុណ ឈុន ប៊ុល

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម ពេជ្រ គឹមសាន្ត
២- ឯកឧត្តម គង់ ផល្លា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

| | | | | |
|---|---|---|---|---|
| ៣- | លោក | គី | ទុន្សី | |
| ៤- | លោក | ស៊ុត | ចាន់ថន | |
| ៥- | វរសេនីយ៍ត្រី | ឃឹម | ចាន់ថុល | អត្តលេខ ០១២៤៣៣ |
| ៦- | លោក | ដាន់ | សាឈាង | |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

| | | | | |
|---|---|---|---|---|
| ១- | លោក | ម៉ុង | មុនីចរិយា | |
| ២- | លោក | ឆៅ | ថន | |
| ៣- | លោក | ឡូន | ឡុន | |
| ៤- | លោក | សុខ | សារឿន | |
| ៥- | លោក | ឌី | សុខុម | |
| ៦- | លោក | សៅ | បុរីវឌ្ឍនៈ | |
| ៧- | លោក | តែ | សឿផាន់ | |
| ៨- | លោក | តែ | ហៀងលី | |
| ៩- | លោកស្រី | សុខ | ស្រីម៉ៅ | |
| ១០- | វរសេនីយ៍ឯក | សុខ | សាគល | អត្តលេខ០០២៨៣២ |
| ១១- | វរសេនីយ៍ទោ | ម៉ែន | យ៉ុន | អត្តលេខ០១០៤៩២ |
| ១២- | លោក | ឌីទ | ប៊ុនថន | |
| ១៣- | វរសេនីយ៍ទោ | ឡាយ | ឆោម | អត្តលេខ០២៣៨០១ |

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

| | | | | |
|---|---|---|---|---|
| ១- | លោក | ហ៊្វ | ទណ្ឌី | |
| ២- | លោក | យី | សៅរ៉ែត | |
| ៣- | លោក | សេង | សុខណាក់ | |
| ៤- | វរសេនីយ៍ត្រី | ជន | ចូរ៉ាមី | អត្តលេខ ០៨៣៣០ |
| ៥- | លោក | ដោក | ទី | |
| ៦- | លោក | ឌិត | ប៊ុនធឿន | |

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

| | | | |
|---|---|---|---|
| ១- | លោក | តាក | សារិទ្ធ |
| ២- | លោក | តែ | ត័ណ្ឌនរ៉ា |
| ៣- | លោក | ឃីម | សុផាត |
| ៤- | លោក | សាន់ | ប៊ុនថន |
| ៥- | អ្នកស្រី | តែ | កលិកា |

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

| | | | | |
|---|---|---|---|---|
| ១- | អនុសេនីយ៍ឯក | អ៊ុយ | សុធា | អត្តលេខ ១៩៦២២៨ |
| ២- | លោក | អ៊ុង | ឆាលី | |
| ៣- | លោក | អ៊ុំ | ផ៊ុង | |
| ៤- | លោក | ពៅ | ចន្ថា | |
| ៥- | លោក | ចាន់ | សុខធី | |
| ៦- | លោក | អៀម | អោ | |
| ៧- | លោក | សុង | ម៉ិនឃាង | |
| ៨- | វរសេនីយ៍ទោ | ហាម | ធីរ៉េត | អត្តលេខ៦១៩៩៥ |
| ៩- | លោក | តាំង | ហេងឃួរ | |
| ១០- | លោក | តាន់ | ទណ្ណាលី | |
| ១១- | លោក | កែក | ពូក | |
| ១២- | លោក | ពិន | សេម | |
| ១៣- | លោក | តាន់ | ស៊ីណា | |
| ១៤- | លោក | ម៉ើង | សុតាព | |

៣៣៧-១៣០១-០៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ: ៤៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

[illegible]យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម សេង ឈួន

ដែលបានខិតខំបំពេញភារកិច្ចជូនជាតិមាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧-១៣០១-០៣៧

លេខៈ ៣៥ ច.ល
**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៣
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៧៥២ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីរបស់រដ្ឋ(អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង) និងចេញពីគម្របព្រៃ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៩៤ គ្រួសារ និងការផ្តល់សិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៥៦២ ឧបប ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់ គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ២៥ ឧបប ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ៤៦ ឧបប ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.**

ត្រូវបានកាត់ដីសរុបទំហំ ៧៥២ ហិកតា ក្នុងនោះទំហំ ៦៤៨ ហិកតា កាត់ចេញពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និងអភិវឌ្ឍន៍ដំណាំឧស្សាហកម្ម និងកែច្នៃ) និងទំហំ ១០៤ ហិកតា កាត់ចេញពីគម្របព្រៃ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅឃុំអូរដា ស្រុកកំរៀង ដែលស្ថិតក្នុងភូមិដូចខាងក្រោម ៖

- ផ្ទៃដីសរុបទំហំ ៤៥២ ហិកតា ក្នុងនោះ ទំហំ ៣៧១.៥០ ហិកតា កាត់ចេញពីពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និងអភិវឌ្ឍន៍ដំណាំឧស្សាហកម្មនិងកែច្នៃ) និងទំហំ ៨០.៥០ ហិកតា កាត់ចេញពីគម្របព្រៃ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦៧ គ្រួសារ នៅភូមិ លំផាត់។
- ផ្ទៃដីសរុបទំហំ ៣០០ ហិកតា ក្នុងនោះ ទំហំ ២៧៦.៥០ ហិកតា កាត់ចេញពីពីដីរបស់រដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហារណ៍នីហារណ៍ និងអភិវឌ្ឍន៍ដំណាំឧស្សាហកម្មនិងកែច្នៃ) និងទំហំ ២៣.៥០ ហិកតា កាត់ចេញពីគម្របព្រៃ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២៧ គ្រួសារ នៅភូមិ ស្វាយជ្រំ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ២.**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៤៩៤ គ្រួសារ នៅឃុំអូរដា ស្រុកកំរៀង ដែលស្ថិតក្នុងភូមិដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦៧ គ្រួសារ នៅភូមិ លំផាត
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១២៧ គ្រួសារ នៅភូមិ ស្វាយជ្រុំ។

**មាត្រា ៣..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៩០២ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៦៧ គ្រួសារ នៅភូមិលំផាត់ ឃុំអូរដា ស្រុកកំរៀង។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៧៧៨ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម ក្នុងនោះ កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន សាម លីញ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១៨ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០២៨ លខ.គច ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៧៧៨ ហិកតា ក្នុងនោះ ទំហំ ១១៣ ហិកតា កាត់ចេញពីគម្របព្រៃឈើ ២០០២ និងទំហំ ៦៦៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សាម លីញ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស្វាយកាំបិត និងភូមិទួលប្រោះ ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១៨ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែងនៅភូមិស្វាយកាំបិត និងភូមិទួលប្រោះ ឃុំសេដា ស្រុកតំបែរ ខេត្តកំពង់ចាម ។

**មាត្រា ៣ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ដីទំហំ ៨០៦,៩៧ ហិកតា នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.០៤៩ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ០០៦ អបខ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីទំហំ ទំហំ ៨០៦,៩៧ ហិកតាចេញពីតម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ៧៧៧,៥៧ ហិកតាសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនិងដីទំហំ ២៩,៤០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែលក្នុងនោះរួមមាន៖

- ផ្ទៃដីទំហំ ៣១,៧៨ ហិកតា កាត់ចេញពីតម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ៣១,៣១ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០,៤៧ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិទំនុបបាក់ ឃុំដំណាក់រាំង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ១៦៩,១៥ ហិកតា កាត់ចេញពីតម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១៦៤,៧៦ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤,៣៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិខ្សាច់ពូន ឃុំដំណាក់រាំង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១និងទី២នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៩៥,៤០ ហិកតា កាត់ចេញពីតម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ៩៥,៥៣ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០,៣៧ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិទួលសំណាង ឃុំដំណាក់រាំង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៨៧,២៨ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ៨៦,០២ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១,២៦ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រពាំងស្មាច់ ឃុំដំណាក់រាំង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ១៩,៧៤ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១៨,៦៤ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ១,១០ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិតាសាល ឃុំជើងរាស់

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៩៥,២៨ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ៩០,៦១ ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤,៦៧ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិយសដោ ឃុំជើងរាស់

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៣៦,៤១ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ៣៤,៣៣ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២,០៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិច្រេស ឃុំជើងរាស់

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៣ និងទី៤នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៣២,២១ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ៣០,៥៧ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១,៦៤ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្រង៉ែ ឃុំជើងរាស់

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៣ និងទី៤ នៃអនុក្រឹត្យនេះ។

- ផ្ទៃដីសរុបទំហំ ២០,៤៩ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ១៧,៨៧ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២,៦២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅក្នុងភូមិអង្គតាប៉ុក ឃុំជើងរាស់

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៧៩,២៧ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ៧៣,២៩ហិកតាសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥,៩៨ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិរូង ឃុំយុទ្ធសាមគ្គី

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ២៥,៣៩ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ២៥,០៩ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ០,៣០ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិត្រាចកោង ឃុំយុទ្ធសាមគ្គី

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៩៣,៩៧ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៩២,៣២ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ១,១៥ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃក្រសាំង ឃុំព្រៃក្រសាំង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ៥៤,៧៥ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៥២,១៨ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ២,៥៧ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិឡ ឃុំព្រៃក្រសាំង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យនេះ។

- ផ្ទៃដីទំហំ ១៥,៩៥ ហិកតា កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១៥,១៥ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០,៨០ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិរមាំងស្លាប់ ឃុំមានជ័យ

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១និងទី៨នៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១.០៤៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដែលក្នុងនោះរួមមាន ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១ គ្រួសារ នៅភូមិទំនុបបាក់ ឃុំដំណាក់រាំង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១០៥ គ្រួសារ នៅភូមិ ខ្សាច់ពូន ឃុំដំណាក់រាំង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៤ គ្រួសារ នៅភូមិទួលសំណាង ឃុំដំណាក់រាំង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៦១ គ្រួសារ នៅភូមិត្រពាំងស្មាច់ ឃុំដំណាក់រាំង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧ គ្រួសារ នៅភូមិតាសាល ឃុំជើងរាស់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១៧ គ្រួសារ នៅភូមិយសជោ ឃុំជើងរាស់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១០៣ គ្រួសារ នៅភូមិច្រេស ឃុំជើងរាស់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៨០ គ្រួសារ នៅភូមិស្រង៉ែ ឃុំជើងរាស់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៨៩ គ្រួសារ នៅក្នុងភូមិអង្គតាប៉ុក ឃុំជើងរាស់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១២២គ្រួសារ នៅភូមិរូង ឃុំយុទ្ធសាមគ្គី
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៤ គ្រួសារ នៅភូមិត្រោចកោង ឃុំយុទ្ធសាមគ្គី
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១១២ គ្រួសារ នៅភូមិព្រៃក្រសាំង ឃុំព្រៃក្រសាំង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៦៥ គ្រួសារ នៅភូមិឡ ឃុំព្រៃក្រសាំង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៩ គ្រួសារ នៅភូមិរមាំងស្លាប់ ឃុំមានជ័យ ។

**មាត្រា ៣ ..**

